# កំណត់សម្គាល់ និងសៀវភៅណែនាំផ្នែកបច្ចេកទេស

## ទំនើបកម្មការគ្រប់គ្រងសាច់ប្រាក់

រៀបចំឡើងដោយលោក អៀន លៀននើត (Ian Liennert)

**ផ្នែកទាំង ៥ នៃកំណត់សម្គាល់នេះ [1]លើកឡើងអំពីបញ្ហាសំខាន់ៗ ដូចខាងក្រោម:**

- តើអ្វីទៅជាទិសដៅរបស់ការគ្រប់គ្រងសាច់ប្រាក់បែបទំនើប?
- តើអ្វីទៅជាការអនុវត្តន៍ល្អក្នុងការគ្រប់គ្រងសាច់ប្រាក់នៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍?
- តើអ្វីទៅជាធាតុសំខាន់ៗនៃក្របខ័ណ្ឌនៃការធ្វើផែនការសាច់ប្រាក់រយៈពេលខ្លី?
- តើអ្វីទៅជាការប្រឈមមុខដ៏ចំបងៗនៅក្នុងការកែលំអការគ្រប់គ្រងសាច់ប្រាក់នៅក្នុងបណ្តាប្រទេស ដែលមានចំណូលទាប និងមធ្យម?
- តើកំណែទម្រង់ការគ្រប់គ្រោងសាច់ប្រាក់ គប្បីត្រូវបានអនុវត្តទៅតាមដំណាក់កាល ដោយរបៀបណា?

---

[1] អត្ថបទដំបូងនៃកំណត់សម្គាល់នេះ ត្រូវបានផ្សព្វផ្សាយកាលពីលើកមុនជាផ្នែកមួយនៃបណ្តាកំណត់សម្គាល់បច្ចេកទេស នៅក្នុងវេបសាយ IMF's Public Financial Management Blog (http://blog-pfm.imf.org) ។ កំណត់សម្គាល់នេះបានទទួលនូវការកែលំអតាមរយៈការពិនិត្យឡើងវិញដោយ B. Olden, G. Ljungman និង H. van Eden, មតិយោបល់ដ៏មានសារៈប្រយោជន៍ពីសហការីដ៏ទៃទៀតនៃ FAD/IMF ដែលរួមមាន R. Allen, D. Bouley, I. Fainboim, M. Lazare, និង M. Pessoa, ក៏ដូចជា មតិយោបល់ដ៏មានតម្លៃពីសំណាក់លោក M. Williams ដែលជាទីប្រឹក្សារបស់ IMF ។

## I. និយមន័យ និងទិសដៅនៃការគ្រប់គ្រងសាច់ប្រាក់

**សាច់ប្រាក់ត្រូវបានអោយនិយមន័យនៅក្នុងសៀវភៅ*ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល***[2]។ នៅក្នុងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល សាច់ប្រាក់ដែលមាននៅក្នុងដៃ គឺសំដៅទៅលើ ក្រដាស់ប្រាក់ កាក់ប្រាក់ និងបញ្ញើសាច់ប្រាក់ ដែលត្រូវបានកម្កល់នៅក្នុងធនាគារ ឬស្ថាប័នហិរញ្ញវត្ថុណាមួយ ទៅតាមតម្រូវការរបស់អង្គភាពស្ថាប័ននៃរដ្ឋាភិបាល ។ សមមូលសាច់ប្រាក់ ត្រូវបានគេអោយនិយមន័យថាជា វិយោគទុន ដែលមានលទ្ធភាពខ្ពស់ក្នុងការប្តូរទៅជាសាច់ប្រាក់ (រូបបិយវត្ថុភាព) ដែលអាចអោយគេបំលែងវាទៅជាសាច់ប្រាក់ទៅតាមសេចក្តីត្រូវការ ។ ការផ្តោតការយកចិត្តដាក់នៃឯកសារនេះ គឺអំពីការគ្រប់គ្រោង "សាច់ប្រាក់ដែលមានក្នុងដៃ" របស់រដ្ឋាភិបាល ។ ប៉ុន្តែ ដូចដែលបានឃើញនៅក្នុងការពិភាក្សាស្តីអំពីការគ្រប់គ្រងសាច់ប្រាក់យ៉ាងសកម្មនោះ, បណ្តារតនាគារផ្សេងៗគ្នា ក៏មានការព្រួយបារម្ភផងដែរ អំពីការគ្រប់គ្រង "សមមូលសាច់ប្រាក់" ។

**ការគ្រប់គ្រងសាច់ប្រាក់គឺជាប្រការចាំបាច់ ពីព្រោះមានភាពខុសគ្នារ វាងពេលវេលានៃការចាយ និងពេលវេលានៃការមានសាច់ប្រាក់** ។ សូម្បីតែ ថវិកាប្រចាំឆ្នាំមានការថ្លឹងថ្លែងត្រឹមត្រូវ ជាមួយនឹងការប៉ាន់ប្រមាណប្រាកដប្រជានៃចំណូល និងចំណាយក៏ដោយ, ការអនុវត្តន៍ថវិកានៅក្នុងឆ្នាំ នឹងមិនមានភាពរលូននោះទេ ពីព្រោះថា ពេលវេលា និងរដូវកាលនៃលំហូរចូលសាច់ប្រាក់ (ដែលពឹងអាស្រ័យទៅលើលំហូរសារពើពន្ធ និងមិនមែនសារពើពន្ធ និងពេលវេលានៃការផ្តល់ជំនួយ ឬកម្ចី) និងពេលវេលា និងរដូវកាលនៃការចំណាយ អាចបង្កអោយមាននូវស្ថានភាពនៃអតិរេកសាច់ប្រាក់បណ្តោះអាសន្ន ឬអោនភាពសាច់ប្រាក់បណ្តោះអាសន្ន ។ ឧទាហរណ៍៖ ប្រសិនពន្ធត្រូវបានបង់ប្រចាំត្រីមាសនោះ, គេអាចមានអតិរេកសាច់ប្រាក់ដ៏ធំបណ្តោះអាសន្ន នៅក្នុងរង្វង់នៃពេលវេលាដែលពន្ធដល់ពេលត្រូវប្រមូល និងអោនភាពសាច់ប្រាក់បណ្តោះអាសន្ន នៅក្នុងពេលវេលាផ្សេងពីនេះ ។

**និយមន័យទាំងអស់នៃការគ្រប់គ្រងសាច់ប្រាក់ ផ្តោតការយកចិត្តទុកដាក់ទៅលើតម្លៃពេលវេលា នៃលុយរបស់រដ្ឋាភិបាល** ។ Storkey (ឆ្នាំ ២០០៣) ផ្តល់នូវនិយមន័យដូចតទៅនេះ៖ "ការគ្រប់គ្រងសាច់ប្រាក់ គឺជាការមានចំនួនលុយត្រឹមត្រូវនៅក្នុងទីកន្លែង និងពេលវេលាត្រឹមត្រូវ ដើម្បីបំពេញកាតព្វកិច្ចចំណាយរបស់រដ្ឋាភិ

---

[2] សូមមើលកថាខ័ណ្ឌ ៤.៤៧ នៃ *GFS Manual*, IMF, 2001 ។

បាល ប្រកបដោយប្រសិទ្ធភាពចំណាយបំផុត” ។ និយមន័យដទៃទៀតផ្តោតការយកចិត្តទុកដាក់ទៅលើការគ្រប់គ្រងបសាច់ប្រាក់សកម្មនៃអតិរេកសាច់ប្រាក់បណ្តោះអាសន្ន និងអោនភាពសាច់ប្រាក់បណ្តោះអាសន្ន[3] ។

**ការគ្រប់គ្រងបសាច់ប្រាក់ទំនើបមានទិសដៅសំខាន់ចំនួនបួនៈ**

- ដើម្បីធានាថាមានសាច់ប្រាក់គ្រប់គ្រាន់ដើម្បីទូទាត់ចំណាយនៅពេលដែលចំណាយត្រូវកើតឡើង ។ ការដាក់រួមបញ្ចូលគ្នានូវចំណូលទៅក្នុងគណនីទោលរតនាគារ ជួយសម្រួលដល់ការងារនេះ ។
- ដើម្បីធ្វើការខ្ចីនៅក្នុងពេលចាំបាច់ និងដើម្បីកាត់បន្ថយនូវការចំណាយទៅលើកម្ចីរបស់រដ្ឋាភិបាលអោយស្ថិតនៅក្នុងកំរិតទាបបំផុត ។
- ដើម្បីធ្វើអតិបរមាកម្មចំណូលពីសាច់ប្រាក់ដែលនៅទំនេរ មានន័យថា ដើម្បីចៀសវាងនូវការផ្តុំបញ្ញើសាច់ប្រាក់របស់រដ្ឋាភិបាលនៅក្នុងធនាគារកណ្តាល ឬនៅក្នុងធនាគារពាណិជ្ជកម្ម ដែលគ្មានការប្រាក់ ឬមានការប្រាក់ទាប ។
- ដើម្បីគ្រប់គ្រងហានិភ័យ តាមរយៈការវិនិយោគនូវអតិរេកសាច់ប្រាក់បណ្តោះអាសន្ន ប្រកបដោយផលិតភាព ដោយមានទ្រព្យបញ្ចាំត្រឹមត្រូវ ។

---

[3] Williams (ឆ្នាំ ២០០៤) អោយនិយមន័យអំពីការគ្រប់គ្រងសាច់ប្រាក់ថាជា “យុទ្ធសាស្ត្រ និងដំណើរដែលពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង ប្រកបដោយការសន្សំសំចៃនូវលំហូរសាច់ប្រាក់រយៈពេលខ្លី និងសមតុល្យសាច់ប្រាក់របស់រដ្ឋាភិបាល ទាំងនៅក្នុងរដ្ឋាភិបាល និងរវាងវិស័យរដ្ឋាភិបាល និងវិស័យដទៃទៀត” ។ នៅក្នុងប្រទេសបារាំង *ការគ្រប់គ្រងសាច់ប្រាក់សកម្ម សំដៅទៅលើការវិនិយោគអតិរេកសាច់ប្រាក់បណ្តោះអាសន្ន នៅក្នុងគណនីដែលមានអត្រាការប្រាប់ខ្ពស់បំផុត និងមានសុវត្ថិភាពខ្ពស់បំផុត ស្របពេលគ្នាជាមួយនឹងការរក្សានូវសមតុល្យឥណទាននៅក្នុងគណនីនោះ ។ សូមមើល Agence France Trésor*—AFT, 2007 ។

ការគ្រប់គ្រងសាច់ប្រាក់ដែលមានប្រសិទ្ធភាព ចូលរួមចំណែកដល់ការអនុវត្តន៍ ប្រកបដោយភាពរលូននូវគោលដៅចំណុចរបស់គោលនយោបាយសារពើពន្ធ យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ និងគោលនយោបាយរូបិយវត្ថុដ៏ទៃទៀត ។

## II. ធាតុសំខាន់ៗនៃការគ្រប់គ្រងសាច់ប្រាក់បែបទំនើប

**យ៉ាងហោចណាស់ ធាតុសំខាន់ៗចំនួន ៩ ត្រូវបានកំណត់ ដើម្បីអោយការគ្រប់គ្រងសាច់ប្រាក់បែបទំនើប មានប្រសិទ្ធភាព នៅក្នុងបណ្តាប្រទេសជឿនលឿន** ។ ធាតុ *ជាមូលដ្ឋានគ្រឹះ*ចំនួន ៦ និងធាតុ *ដែលគេចង់បាន*ចំនួន ៣ ត្រូវបានកំណត់នៅក្នុងប្រអប់ ១ ។ ធាតុទាំង ៩ នេះ ត្រូវបានអនុវត្តន៍នៅក្នុងបណ្តាប្រទេស OECD ដែលមានការរីកចំរើន ។

### ការពិភាក្សាអំពីធាតុជាមូលដ្ឋានគ្រឹះមួយចំនួននៃគ្រប់គ្រងសាច់ប្រាក់ដែលមានប្រសិទ្ធភាព

**ការធ្វើមជ្ឈការសមតុល្យសាច់ប្រាក់រដ្ឋាភិបាល - ការបង្កើតប្រព័ន្ធគណនីទោលរតនាគារ[4] - មានសារៈសំខាន់ណាស់** ។ នៅក្នុងប្រទេសជឿនលឿនភាគច្រើនបំផុត, ចំណូលស្ទើរតែទាំងអស់ ត្រូវបញ្ចូលគ្នាជារៀងរាល់ថ្ងៃនៅក្នុងគណនីទោលរតនាគារ ដែលស្ថិតនៅក្នុងក្នុងការឃុំគ្រងមាំទាំរបស់រតនាគាររបស់ក្រសួងហិរញ្ញវត្ថុ [5] ។ តាមរយៈគណនីទោលរតនាគារ ក្រសួងហិរញ្ញវត្ថុមានលទ្ធភាពពេញលេញក្នុងការប្រើប្រាស់នូវធនធានសាច់ប្រាក់ទាំងអស់នោះ ដែលត្រូវបានតម្កល់នៅក្នុងបណ្តាក្រសួង និងស្ថាប័នថ្នាក់កណ្តាលនៃរដ្ឋាភិបាល នៅក្នុងគ្រប់ពេលវេលាជាក់លាក់ណាមួយ ។ គណនីមេនៃប្រព័ន្ធគណនីទោលរតនាគារ ត្រូវបានរក្សានៅក្នុងធនាគារកណ្តាល និងត្រូវបានប្រើប្រាស់សម្រាប់ទទួលនូវចំណូលទាំងអស់របស់រដ្ឋាភិបាល និងធ្វើ

---

[4] ការបង្កើតឡើងនូវគណនីទោលរតនាគារ ត្រូវបានពិភាក្សាពេញលេញជាងនេះ នៅក្នុងឯកសាររបស់ Fainboim, Israel និង Pattanayak, Sailendra. *ឆ្នាំ ២០០៩, គណនីទោលរតនាគារ: គោលគំនិត, ប្លង់ និងបញ្ហានៃការអនុវត្តន៍,* ឯកសារសម្រាប់ការពិភាក្សានៃ IMF, នឹងចេញផ្សព្វផ្សាយក្នុងពេលឆាប់ៗខាងមុខ ។

[5] នៅក្នុងឯកសារនេះ “ក្រសួងហិរញ្ញវត្ថុ” និង “រតនាគារ” ត្រូវបានប្រើប្រាស់ជាទូទៅ ។ រតនាគារ តំណាងអោយនាយកដ្ឋាន នៅក្នុង ក្រសួងហិរញ្ញវត្ថុ ដែលនាយកដ្ឋាននេះទទួលខុសត្រូវទៅលើការគ្រប់គ្រងសាច់ប្រាក់ថ្នាក់កណ្តាល និងការគ្រប់គ្រងបំណុល ទោះបីជាវាជាអង្គភាពដាច់ដោយឡែក ដែលមានស្វ័យតិភាពមួយកំរិតណាមួយក៏ដោយ (រចនាសម្ព័ន្ធស្ថាប័ន មានភាពខុសគ្នារវាងប្រទេសផ្សេងៗគ្នា) ។

ការទូទាត់ចំណាយរដ្ឋាភិបាល ។ នៅក្នុងពេលបង្កើតគណនីទោលរតនាគា មុខងារទូទាត់ចំណាយរបស់រដ្ឋាភិបាល ត្រូវបានធ្វើមជ្ឈការ (ឧ. បារាំង, អាឡឺម៉ង់ និងសហរដ្ឋអាមេរិក) - ដែលការទូទាត់ទាំងអស់ត្រូវបានធ្វើឡើងដោយផ្ទាល់ចេញពីគណនីប្រតិបត្តិមេនៃប្រព័ន្ធគណនីទោលរតនាគារ ដែលត្រូវបានរក្សានៅក្នុងធនាគារកណ្តាល (លើកលែងតែករណីមួយចំនួនតូច) ។ ផ្ទុយទៅវិញការទូទាត់ចំណាយអាចត្រូវបានធ្វើវិមជ្ឈការ និងអាចត្រូវបានធ្វើឡើង ដោយក្រសួងចំណាយចេញពីគណនី ដែលត្រូវបានរក្សានៅក្នុងធនាគារពាណិជ្ជកម្ម[6] ។ រៀងរាល់ថ្ងៃ សមតុល្យនៅក្នុងគណនីរបស់ក្រសួង/ស្ថាប័នទាំងអស់នោះ ត្រូវបានបញ្ចូលទៅក្នុងគណនីទោលរតនាគារ ហើយអ្នកគ្រប់គ្រងសាច់ប្រាក់រដ្ឋាភិបាល ត្រូវធានាអោយមានតែសមតុល្យអប្បបរមាចុងថ្ងៃប៉ុណ្ណោះ នៅក្នុងគណនីមេនៃ TSA នៅក្នុងធនាគារកណ្តាល ។ អតិរេកសាច់ប្រាក់បណ្តោះអាសន្ន តាមធម្មតាកើតឡើងដោយសារការប្រាក់ដែលត្រូវបានសងដោយធានាគារកណ្តាល ឬការប្រាក់ពីការវិនិយោគនៅក្នុងទីផ្សារហិរញ្ញវត្ថុ (បញ្ហានេះត្រូវបានពិភាក្សាពេញលេញជាងនេះនៅផ្នែកខាងក្រោម) ។

## ប្រអប់ ១ ÷ ធាតុផ្សំ ៩ នៃការគ្រប់គ្រងសាច់ប្រាក់បែបទំនើប

**ធាតុជាមូលដ្ឋានគ្រឹះ**

- មជ្ឈការកម្មសមតុល្យសាច់ប្រាក់រដ្ឋាភិបាល និងការបង្កើតឡើងនូវរចនាសម្ព័ន្ធគណនីទោលរតនាគារ ។
- ការយល់ច្បាស់លាស់អំពីការគ្របដណ្តប់នៃក្របខ័ណ្ឌធ្វើផែនការសាច់ប្រាក់ ។
- សមត្ថភាពធ្វើការព្យាករណ៍បានត្រឹមត្រូវនូវលំហូរចូល-លំហូរចេញសាច់ប្រាក់រយៈពេលមធ្យម ។

---

[6] ឧទាហរណ៍, នៅក្នុងប្រទេសអូស្ត្រាលី ស្ថាប័នចំណាយ មិនមែនត្រឹមតែទទួលខុសត្រូវទៅលើការផ្តល់ការយល់ព្រមដល់ចំណាយ និងការត្រួតពិនិត្យផ្ទៃក្នុងតែប៉ុណ្ណោះទេ ប៉ុន្តែទទួលខុសត្រូវទៅលើការគ្រប់គ្រងសាច់ផ្ទៃក្នុងផងដែរ ។ ទោះបីជាប្រតិបត្តិការហិរញ្ញវត្ថុ ត្រូវបានចេញពីគណនីធនាគាររបស់ស្ថាប័នក៏ដោយ គ្រប់សមតុល្យចុងថ្ងៃត្រូវបានបញ្ចូលទៅក្នុងគណនីទោលរតនាគារនៅក្នុងធានាគាបំរុងនៃប្រទេសអូស្ត្រាលី ។ ជាក់ស្តែង, មានប្រពន្ធគ្រប់គ្រងសាច់ប្រាក់ទ្វេរកំរិត: មួយនៅក្នុងថ្នាក់ស្ថាប័នចំណាយ និងមួយទៀតដែលជាប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់សរុបបញ្ចូលគ្នា នៅឯថ្នាក់កណ្តាល ។

- ក្របខ័ណ្ឌគតសមស្រប សម្រាប់ការចាត់ចែង និងការធ្វើគណនេយ្យកម្មប្រតិបត្តិការ ។
- ការចែករំលែកពត៌មានទាន់ពេលវេលា រវាងរតនាគារកណ្តាល, ស្ថាប័នប្រមូលចំណូល, ក្រសួងចំណាយ និង/ឬការិយាល័យសាខានៃរតនគារ ។
- រចនាសម្ព័ន្ធស្ថាប័ន និងការទទួលខុសត្រូវត្រឹមត្រូវ ។

**ធាតុដែលគេចង់បាន**

- ការប្រើប្រាស់ប្រព័ន្ធទំនើបសម្រាប់ការងារធនាគារ, ការបង់ប្រាក់ និងការទូទាត់ ។
- ការប្រើប្រាស់នូវយន្តការទីផ្សារហិរញ្ញវត្ថុរយៈពេលខ្លី សម្រាប់ការគ្រប់គ្រងសាច់ប្រាក់ ។
- សមាហរណកម្មនៃការគ្រប់គ្រងបំណុល និងសាច់ប្រាក់ ។

**ការគ្របដណ្តប់នៃក្របខ័ណ្ឌគ្រប់គ្រងសាច់ប្រាក់ត្រូវបានកំណត់ច្បាស់លាស់** ។ ក្របខ័ន្ឋម៉ាក្រូហិរញ្ញវត្ថុទូទៅសម្រាប់ “រដ្ឋាភិបាលទូទៅ” (និយមន័យស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបា) ជារឿយៗរួមបញ្ចូលគ្នានូវចំណូល និងចំណាយ ដែលមិនត្រូវបានបញ្ចូលនៅក្នុងថវិកាប្រចាំឆ្នាំនៃរដ្ឋាភិបាលថ្នាក់កណ្តាល ។ ឧទាហរណ៍: នៅក្នុងបណ្តាប្រទេស OECD មូលនិធិក្រៅថវិកាសម្រាប់សន្តិសុខសង្គម កើតមានឡើងជាទូទៅ ។ នៅក្នុងប្រទេសជឿនលឿនមួយចំនួន ការគ្របដណ្តប់នៃមូនិធិសម្រាប់ការគ្រប់គ្រងសាច់ប្រាក់សាច់សកម្ម មានកំរិតខ្ពស់យ៉ាងច្រើនជាងថវិការដ្ឋាភិបាលថ្នាក់កណ្តាល [7]។ នៅក្នុងបណ្តាប្រទេសដែលមានចំណូលទាប ការចំណាយមួយចំនួនដែលត្រូវបានផ្តល់ហិរញ្ញប្បទានដោយនម្ចាស់ជំនួយ ឬកម្ចីពហុភាគីនោះ អាចមិនត្រូវបានបញ្ចូល

---

[7] ប្រទេសបារាំងគឺជាឧទាហរណ៍ខ្ពស់ជាងគេបំផុត: ភ្នាក់ងារគ្រប់គ្រងសាច់ប្រាក់ និងបំណុល (*Agence France Trésor*) ធ្វើការគ្រប់គ្រងមិនមែនតែត្រឹមសមតុល្យសាច់ប្រាក់នៃរដ្ឋាភិបាលថ្នាក់កណ្តាលនោះទេ ប៉ុន្តែគ្រប់គ្រងផងដែរនូវសមតុល្យសាច់ប្រាក់នៃរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងស្ថាប័នសាធារណៈមួយចំនួនទៀត ។ នៅក្នុងបណ្តាប្រទេសសហព័ន្ធ, ដោយសារឯករាជ្យភាពនៃរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ប៉ុន្តែក៏ដោយសារតែភាពស្មុគស្មាញក្នុងការព្យាករណ៍អំពីតម្រូវការសាច់ប្រាក់ប្រចាំថ្ងៃនៅក្នុងគ្រប់ថ្នាក់ទាំងអស់នៃរដ្ឋាភិបាលផងដែរ, សកម្មភាពគ្រប់គ្រងសាច់ប្រាក់នៅរតនាគារ ស្ថិតនៅក្នុងរង្វង់នៃលំហូរសាច់ប្រាក់ ដែលពាក់ព័ន្ធទៅនឹងថវិការដ្ឋាភិបាលថ្នាក់កណ្តាល តែប៉ុណ្ណោះ ។

នៅក្នុងថវិកាប្រចាំឆ្នាំ ដែលត្រូវបានអនុម័តិដោយសភាជាតិនៃប្រទេសទទួលជំនួយ ។ ទោះបីជាមូលនិធិរបស់ម្ចាស់ជំនួយត្រូវបានបញ្ចូលនៅក្នុងថវិកាប្រចាំឆ្នាំក៏ដោយ សាច់ប្រាក់ដែលមានសម្រាប់ការផ្តល់ហិរញ្ញប្បទានដល់ការចំណាយដែលពាក់ព័ន្ធនោះ ជារឿយៗត្រូវបានរក្សានៅក្នុងគណនីពិសេស ដាច់ដោយឡែកពីគណនីទោលរតនាគាររបស់រដ្ឋាភិបាល ដែលស្ថិតនៅក្នុងធនាគារកណ្តាល ។ ជាទូទៅ ដើម្បីអោយការប្រមូលផ្តុំសាចប្រាក់រដ្ឋាភបាលអាចធ្វើទៅបាន ប្រកបដោយប្រសិទ្ធភាពនោះ ប្រការចាំបាច់នោះគឺថារតនគារអាចដឹងបានអំពីសមតុល្យសាច់ប្រាក់នៃមូលនិធិថវិកាបន្ថែម ។ ដូចនេះ ការគ្រប់ដណ្តប់នៃមូលនិធិដែលមានសម្រាប់ការគ្រប់សាច់ប្រាក់គប្បីត្រូវបានកំណត់ច្បាស់លាស់ ។

**ការធ្វើផែនការ និងការព្យាករណ៍សាច់ប្រាក់រយ:ពេលខ្លី:** ការគ្រប់គ្រងសាច់ប្រាក់ប្រកបដោយប្រសិទ្ធភាព អាចកើតឡើងបាន តែនៅក្នុងករណីណាដែលគេមានជំនាញ និងសមត្ថភាពក្នុងការកត់ត្រា, តាមដាន និងធ្វើការព្យាករណ៍នូវលំហូរចេញ និងលំហូរចូលសាច់ប្រាក់រយ:ពេលខ្លី ក្នុងគណនីទោលរតនាគារ តែប៉ុណ្ណោះ ។ ក្របខ័ណ្ឌសម្រាប់ការធ្វើផែនការសាច់ប្រាក់រយ:ពេលខ្លី ត្រូវបានពិភាក្សានៅក្នុងផ្នែក III ។

**ការចាត់ចែងប្រតិការបានត្រឹមត្រូវ, ក្របខ័ណ្ឌគណនេយ្យកិច្ច, រចនាសម្ព័ន្ធស្ថាប័ន និងការចែករំលែកពត៏មាន:** ដើម្បីធ្វើការព្យាករណ៍រយ:ពេលខ្លី, អ្នកគ្រប់គ្រងសាច់ប្រាក់ ត្រូវការមាននូវទិន្នន័យគ្រប់គ្រាន់យូរលង់តាមលំដាប់លំដោយពេលវេលា សម្រាប់ការព្យាករណ៍នូវលំហូរចូល និងលំហូរចេញទាំងអស់ពី គណនីទោលរតនាគារ (ការផ្ទេរចំណូល, ការទូទាត់ចំណាយ, ប្រតិបត្តិការបំណុល ។ល។) ។ នៅក្នុងប្រទេសជឿនលឿនទិន្នន័យដែលមានគុណភាពខ្ពស់, ទាន់ពេលវេលា និងមានភាពពេញលេញស្តីអំពីប្រតិបត្តិការសាច់ប្រាក់រដ្ឋាភិបាល តាមធម្មតាមានជាស្រេចនៅក្នុងប្រព័ន្ធគណនេយ្យរបស់រដ្ឋាភិបាល ដែលត្រូវបានរក្សាពេញលេញដោយប្រព័ន្ធកុំព្យូទ័រ ។ សម្រាប់ការព្យាករណ៍សាច់ប្រាក់រយ:ពេលខ្លី
តួអង្គដែលពាក់ព័ន្ធ ចូលរួមចំណែកផ្តល់នូវទិន្នន័យចាំបាច់ ។ បណ្តាញចែករំលែកពត៏មានត្រូវបានបង្កើតឡើង និងមានការយល់ដឹងច្បាស់លាស់អំពីការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋាភិបាលនីមួយៗ ចំពោះធាតុផ្សេងៗគ្នានៃការគ្រប់គ្រងសាច់ប្រាក់ ។

**ការព្យាករណ៍ថវិកាដែលមានលក្ខណ:ប្រាកដប្រជា និង/ឬការព្យាករណ៍ចំណូលប្រកបដោយការប្រុងប្រយ័ត្ន ជួយអោយគេអាចចៀសវាបាននូវបញ្ហាក្នុងការគ្រប់គ្រប់សាច់ប្រាក់** ។ ប្រទេសជឿនលឿនមួយចំនួន មានចេតនា

ធ្វើការប៉ាន់ប្រមាណទាបទៅលើកំណើនសេដ្ឋកិច្ច និងចំណូលថវិការបស់ខ្លួន [8] ។ ទោះបីជាការព្យាករណ៍បែបនេះ ត្រូវបានធ្វើឡើងជាសំខាន់ដើម្បីការប្រុងប្រយ័ត្នផ្នែកសេដ្ឋកិច្ច- ការចៀសវាង ឬការកាត់បន្ថយនូវអោនភាពសេដ្ឋកិច្ចខ្លាំងពេក - ការអនុវត្តន៍បែបនេះ ផ្តល់នូវផលប៉ះពាល់ល្អទៅលើការគ្រប់គ្រងសាច់ប្រាក់ ជាពិសេសនៅក្នុងប្រទេសដែលមានទីផ្សារហិរញ្ញវត្ថុមានកំរិត ឬគ្មានតែម្តង ។ នៅក្នុងពេលដែលចំណូលមានកំរិតទាបជាងការព្យាករណ៍ចំណាយដែលទាបនោះ, គេមានតំរូវការតិចតួចក្នុងការង្កើននូវការត្រួតពិនិត្យការចំណាយ (expenditure controls) ដែលត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់ការគ្រប់គ្រងសាច់ប្រាក់ នៅក្នុងប្រទេសដែលមានចំណូលទាប ។

## ការអនុវត្តន៍ល្អសម្រាប់ការគ្រប់គ្រងសមតុល្យសាច់ប្រាក់ប្រចាំថ្ងៃ

### បណ្តាប្រទសជឿនលឿនភ្ជាប់សារៈសំខាន់ខ្ពស់ទៅលើការបាត់បង់ឱកាសដោយសារការរក្សាទុកនូវសាច់ប្រាក់ដែលមិនបានប្រើការអ្វីសោះ ។

ការរក្សាទុកនូវក្រដាសប្រាក់ ឬសាច់ប្រាក់របស់រដ្ឋាភិបាល នៅក្នុងគណនីធនាគារដែលមិនមានការប្រាក់នោះ គឺជាការខាតបង់យ៉ាងច្រើន ។ ការដាក់អតិរេកសាច់ប្រាក់បណ្តោះអាសន្ននៅក្នុងយន្តការហិរញ្ញវត្ថុដែលផ្តល់នូវផលចំណេញទាបនោះ ក៏អាចនាំអោយមានការខាតបង់ហិរញ្ញវត្ថុផងដែរ សម្រាប់រដ្ឋាភិបាល ។ ដូចគ្នានេះដែរ ការពន្យារចំណូល (revenue float), មានន័យថា ការយឺតយ៉ាវនៅក្នុងការផ្ទេរចំណូលចេញពីគណនីរដ្ឋាភិបាលក្នុងធនាគារពាណិជ្ជ ទៅកាន់គណនីទោលរតនាគារ, គឺជាខាតបង់ ។ នៅក្នុងប្រទេសខ្លះគេត្រូវរង់ចាំជាច្រើនថ្ងៃមុនពេលចំណូលចូលមកដល់គណនីទោលរតនាគារ ។ នេះគឺជាឧបត្ថម្ភធនលាក់មុខនៃរដ្ឋាភិបាល សម្រាប់ធនាគារពាណិជ្ជកម្ម [9] ។ ដូចគ្នានេះដែរ ការពន្យារចំណាយ នៅក្នុងគណនីចំណាយរ

---

8 ការវិភាគអំពីការព្យាករណ៍ថវិកានៅក្នុងបណ្តាប្រទេស OECD ចំនួន ១១ បានបង្ហាញថាភាគច្រើននៃប្រទេសទាំងនេះ (ជាពិសេសប្រទេសកាណាដា) ធ្វើការព្យាករណ៍ទាបអំពីចំណូលរបស់គេ ដោយចេតនា ។ (សូមមើលជំពូក VI នៃឯកសាររបស់ IMF, ឆ្នាំ ២០០៧) ។

9 ធនាគារពាណិជ្ជកម្មនៅក្នុងបណ្តាប្រទេសអាមេរិកឡាទីនជាច្រើន មិនមែន "ទទួលបាននូវកំរៃ" ជាក់ស្តែងដោយផ្ទាល់ទេ ពីការផ្តល់សេវាទៅអោយរតនាគារ ។ ផ្ទុយមកវិញ ធនាគារទាំងនោះ ទទួលបាននូវអត្ថប្រយោជន៍ពីការ

ដ្ឋាភិបាល - ការផ្តល់លុយចេញពីគណនីទោលរតនាគារទៅកាន់គណនី "បណ្តោះអាសន្ន - transit account" មុនថ្ងៃដែលការទូទាត់ជាក់ស្តែងកើតឡើង - ក៏ផ្តល់នូវឧមត្ថម្ភធនលាក់មុខងដែរ ទៅអោយធនាគារពាណិជ្ជកម្ម (ឬធនាគារកណ្តាល នៅក្នុងពេលដែលរដ្ឋាភិបាលធ្វើការទូទាត់ចេញគណនីរបស់ខ្លួននៅក្នុងធនាគារកណ្តាល) ។ ចុងក្រោយបង្អស់, ម្ចាស់ពន្ធ គឺជាអ្នកដែលរ៉ាប់រងនូវការខាតបង់ឱកាសនោះ ពីការពន្យារនៅក្នុងធនាគារ និងបញ្ញើសាច់ប្រាក់របស់រដ្ឋាភិបាលដែលមិនទទួលបាននូវកំរៃអ្វីសោះ ។ ដោយទទួលស្គាល់នូវតម្លៃពេលវេលានៃលុយរបស់រដ្ឋាភិបាលនោះ អ្នកគ្រប់គ្រងសាច់ប្រាក់នាសម័យទំនើប បានប្រកាន់យកនូវការអនុវត្តន៍ ដែលត្រូវបានពិពណ៌នានៅក្នុងប្រអប់ ២ ។

### ប្រអប់ ២ ÷ ការទទួលស្គាល់តម្លៃពេលវេលានៃសាច់ប្រាក់ ដែលត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល

- *ធនធានសាច់ប្រាក់របស់រដ្ឋាភិបាលត្រូវបានប្រមូលផ្តុំ*នៅក្នុងគណនីទោលរតនាគារ ។
- *សមតុល្យសាច់ដែលនៅទំនេរត្រូវបានកាត់បន្ថយអោយមានកំរិតទាបបំផុត ដែលនាំអោយគេចៀសវាបាននូវកម្ចីមិនចាំបាច់របស់រដ្ឋាភិបាល ។*
- បញ្ញើសាច់ប្រាក់របស់រដ្ឋាភិបាល ដែលមិនមានកំរៃឬការប្រាក់នៅក្នុងប្រព័ន្ធធនាគារ ត្រូវបានចៀសវាង ។
- *គ្មានការពន្យារចំណូល និងចំណាយ (revenue and expenditure float) ។* រាល់គណនីទាំងអស់របស់រដ្ឋាភិបាលដែលមិនមែនជាគណនីទោលរតនាគារ មានសមតុល្យសាច់ប្រាក់សូន្យ នៅចុងថ្ងៃនីមួយៗ ។
- *ប្រតិបត្តិការត្រូវបានធ្វើឡើងតាមប្រព័ន្ធធនាគារ ។* ប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានធ្វើឡើងក្នុងកំរិតអតិបរមា ដែលជាហេតុនាំអោយមានការកាត់បន្ថយនូវការពន្យារនូវប្រតិបត្តការ និងជាជំ

---

យឺតយ៉ាវយូរអង្វែង នៅក្នុងផ្ទេរចំណូលពន្ធ ចេញពីប្រាក់បញ្ញើរបស់ម្ចាស់ពន្ធនៅក្នុងធនាគារទាំងនេះ ទៅកាន់គណនីទោលរតនាគាររបស់រដ្ឋាភិបាល ។ ឧទាហរណ៍: ៣ ថ្ងៃនៅក្នុងប្រទេសអេក្វាទ័រ, ម៉ិកស៊ិកូ និបប៉េរូ និង ១៥ ថ្ងៃ នៅក្នុងប្រទេសកូឡំប៊ី ។

ហានៗ ដើរតួជំនួសអោយមូលប្បទានប័ត្រដែលត្រូវបានអនុវត្តនៅក្នុងប្រព័ន្ធបើកប្រាក់ (payment clearing systems)។ ការអនុវត្តន៍បែបនេះ មានភាពផ្ទុយគ្នានឹងការអនុវត្តន៍ ដែលត្រូវបានធ្វើឡើងក្នុងប្រទេស ដែលមានប្រព័ន្ធបើកប្រាក់មិនមានប្រសិទ្ធិភាព និងប្រព័ន្ធធនាគារទន់ខ្សោយ ដែលអាចពាក់ព័ន្ធទៀតផងជាមួយនឹងការដឹកជញ្ជូនសាច់ប្រាក់ជាក់ស្តែង (ក្រដាសប្រាក់) ។

- *ធនាគារដែលផ្តល់សេវាធនាគារ ត្រូវបានផ្តល់កំរៃក្នុងមួយប្រតិបត្តិការម្តង* អាស្រ័យទៅតាមតម្លៃនៃប្រតិបត្តិការនោះ ។ ធនាគារដែលមានសមត្ថភាព ត្រូវនាជ្រើសរើសដោយការដេញថ្លៃប្រកួតប្រជែង សម្រាប់ការផ្តល់សេវាផ្ទេរចំណូល និង/ឬបើកប្រាក់ ជំនួសអោយរដ្ឋាភិបាល ។ សមត្ថភាពរបស់ធនាគារ ក្នុងការផ្ទេរបានឆាប់រហ័សនូវសមតុល្យចូលទៅក្នុងគណនីទោលរតនាគារវិញ ដែលបំបាត់នូវសមតុល្យទំនេរនោះ មានសារៈសំខាន់ណាស់ ។

- *ការទូទាត់ (ការបើកប្រាក់) ត្រូវបានធ្វើឡើងភ្លាមៗ* ។ អាស្រ័យហេតុនេះ ការយឺតយ៉ាវនូវការទូទាត់ (ការបើកប្រាក់) និងការផាកពិន័យដោយសារការបើកប្រាក់យឺតយ៉ាវនោះ ត្រូវបានចៀសវាង ។

- *កំរិតសាច់ប្រាក់ (targets) សម្រាប់សមតុល្យចុងថ្ងៃក្នុងគណនីទោលរតនាគារ តាមធម្មតាត្រូវបានកំណត់* [10] ។ រាល់កង្វះខាតសាច់ប្រាក់ដែលមិនត្រូវបានរំពឹងទុក (ឧ. ដោយសារភាពខុសគ្នានៃពេលវេលា) អាចត្រូវបានផ្តល់ហិរញ្ញប្បទានតាមរយៈកម្ចីរយៈពេលខ្លី នៅក្នុងទីផ្សារភាគហ៊ុន ឬតាមរយៈប្រព័ន្ធធនាគារ, ដើម្បីកាត់បន្ថយអោយមបានទាបបំផុតនូវតំរូវការរក្សាទុកសមតុល្យសាច់ប្រាក់ ដ៏ច្រើនដែលទទួលបាននូវផលចំណេញទាប ។

- អតិរេកបណ្តោះអាសន្ននៅក្នុងគណនីទោលរតនាគារ ត្រូវបានវិនិយោគនៅក្នុងយន្តការហិរញ្ញវត្ថុដែលគិតការប្រាក់ ដែលតាមធម្មតាមានការធានាពេញលេញ ដើម្បីកាត់បន្ថយហានិភ័យអោយស្ថិតនៅក្នុងកំរិតទាបបំផុត ។ មានការចូលរួមកាន់តែច្រើនឡើង ពីសំនាក់រតនាគារនៅក្នុងទីផ្សារកំរិតទីពីរ (secondary markets) សម្រាប់មូលធនប័ត្ររដ្ឋាភិបាល (securities) ជាមួយនឹងទ្វេរទិសដៅ ដើម្បី

---

[10] ឧទាហរណ៍: សមតុល្យចុងថ្ងៃនៅក្នុងប្រទេសបារាំង, ចក្រភពអង់គ្លេស, និងសហរដ្ឋអាមេរិក គឺតាមលេខរៀង ១០០លានអឺរ៉ូ, ប្រហាក់ប្រហែល ២០០លានផោនដ៍ (ពិព្រោះថា វាប្រែប្រួលពីសប្តាហ៍មួយទៅសប្តាហ៍មួយទៀត) និង ៥-៧ពាន់លានដុល្លា ។

ធ្វើអតិបរមាកម្មចំណូលអំពីសមតុល្យសាច់ប្រាក់ដែលមាន និងដើម្បីចៀសវាងនូវភាពខុសគ្នានៃពេលវេលា ។

**ការយកអត្ថប្រយោជន៍ពីប្រពន្ធ័ធនាគារទំនើប និងយន្តការហិរញ្ញវត្ថុ ។** ការគ្រប់គ្រងសាច់ប្រាក់បានល្អ ត្រូវបានជួយសម្រួល នៅក្នុងពេលដែលប្រតិបត្តិការទាំងអស់របស់រដ្ឋាភិបាលត្រូវបានធ្វើឡើង តាមរយៈប្រព័ន្ធធនាគារទំនើប, មានន័យថា ជាប្រព័ន្ធមួយដែលក្នុងនោះធនាគារពាណិជ្ជកម្ម ត្រូវបានភ្ជាប់គ្នាដោយបណ្តាញអេឡិចត្រូនិកជាមួយសាខាផ្ទាល់ខ្លួនរបស់គេ និងនៅក្នុងពេលដែលប្រព័ន្ធទូទាត់អន្តរធនាគារ ត្រូវបានបង្កើតឡើងត្រឹមត្រូវ និងត្រូវបានបញ្ចូលជាផ្នែកមួយនៅក្នុងប្រព័ន្ធទូទាត់របស់ធនគារកណ្តាល តាមរយៈប្រព័ន្ធទូទាត់ទាំងដុលភ្លាមៗ (real time gross settlement (RTGS) systems) ។ រតនគារទំនើបទទួលបានអត្ថប្រយោជន៍ពីឧបករណ៍បែបនេះ និងប្រើប្រាស់នូវវិធីសាស្ត្រផ្ទេរចំណូល និង ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ។ នៅក្នុងបណ្តាប្រទេសជឿនលឿន នៅក្នុងពេលដែលគេមានកង្វះខាតសាច់ប្រាក់ ឬអតិរេកសាច់ប្រាក់បណ្តោះអាសន្ន អ្នកគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋាភិបាល ដែលជាអ្នកតាមដានសមតុល្យសរុបរួមគ្នាប្រចាំថ្ងៃរបស់បណ្តាគណនីរដ្ឋាភិបាលនោះ នឹងធ្វើការខ្ចីគេ ឬអោយគេខ្ចីនៅក្នុងទីផ្សារហិរញ្ញវត្ថុ ។ ឧទាហរណ៍, នៅក្នុងបណ្តាប្រទេសអឺរ៉ុប រតនាគារជារឿយៗមានសភាពសកម្មនៅក្នុងទីផ្សារលក់ និងទិញមូលធនប័ត្រឡើងវិញ (repo markets) [11]។ នៅក្នុងពេលដែលរតនាគារគឺជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងទីផ្សារនោះ វានាំអោយមាននូវផលប៉ះពាល់វិជ្ជមានទីដល់ការវិវត្តន៍នៃទីផ្សារលុយ ។

---

[11] កិច្ចព្រមព្រៀងលក់ហើយទិញវិញ (repurchase agreement ឬ repo) គឺជាឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានប្រើប្រាស់ដោយក្រសួងហិរញ្ញវត្ថុ ដើម្បីទទួលបានសាច់ប្រាក់ តាមរយៈការលក់មូលធនប័ត្រ ដែលតាមធម្មតាគឺប័ណ្ណរតនាគារ (Treasury bill) ឬប័ណ្ណបំណុលរបស់រដ្ឋាភិបាល (government bond) ។ កិច្ចសន្យាទិញហើយលក់វិញ (reverse repo) ត្រូវបានប្រើប្រាស់ដោយក្រសួងហិរញ្ញវត្ថុ ដោយការបញ្ចេញសាច់ប្រាក់បណ្តោះអាសន្ន ដើម្បីទិញមូលធនប័ត្រ (មានន័យថា ប័ណ្ណរតនាគារ ឬប័ណ្ណបំណុលរបស់រដ្ឋាភិបាល) ដោយមានការឯកភាពគ្នាថាប្រតិបត្តិការបែបនេះ នឹងត្រូវបានលក់ទៅវិញនៅក្នុងថ្ងៃអនាគត ។ សមកម្មភាពទីផ្សារលក់ និងទិញឡើវិញ ត្រូវបានធានាពេញលេញ ។ ក្រៅពីការចូលរួមនៅក្នុងទៅផ្សារមូលធន, រតនាគារនៅក្នុងបណ្តាប្រទេសមួយចំនួនតូច ធ្វើការខ្ចី ឬអោយគេខ្ចី នៅក្នុងទីផ្សារហិរញ្ញវត្ថុដែលមានសុវត្ថិភាព ប៉ុន្តែនៅក្នុងកំរិតត្បិតត្បៀតយ៉ាងខ្លាំង ។

**ការបង្កើតអោយមាននូវរចនាសម្ព័ន្ធស្ថាប័ន្ធត្រឹមត្រូវ និងការទទួលខុសត្រូវច្បាស់លាស់ ។** នៅក្នុបណ្តាប្រទេសជឿនលឿន គេមានការយល់ដឹងច្បាស់លាស់ រវាងអ្នកគ្រប់គ្រងសាច់ប្រាក់នៃក្រសួងហិរញ្ញវត្ថុ និងស្ថាប័នដទៃទៀត ជាពិសេសធនាគារកណ្តាល និងធនាគារពាណិជ្ជកម្ម អំពីតួនាទីរៀងៗខ្លួនរបស់គេនៅក្នុងការគ្រប់គ្រងសាច់ប្រាក់ និងការគ្រប់គ្រងបំណុល ។ ក្នុងនាមជាអ្នកគ្រប់គ្រងថ្នាក់កណ្តាលនៃសាច់ប្រាក់រដ្ឋាភិបាល ក្រសួងហិរញ្ញវត្ថុ ធ្វើការនាំមុខគេនៅក្នុងការចរចារអោយមាននូវពិធីសារអំពីការយោគយល់គ្នា ដែលចែងអំពី (១) តួនាទីដែលក្រសួងហិរញ្ញវត្ថុអាចផ្ទេរទៅអោយធនាគារពាណិជ្ជកម្ម និង/ឬធនាគារកណ្តាល, ឧទាហរណ៍: ការប្រមូលចំណូលតាមប្រព័ន្ធអេឡិចត្រូនិក ឬការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកទៅលើការចំណាយផ្សេងៗគ្នារបស់រដ្ឋាភិបាល (ការទូទាត់រូបិយវត្ថុបរទេស តាមធម្មតា ត្រូវបានធ្វើឡើងដោយធនាគារកណ្តាល ដោយសារបញ្ហាទីផ្សារបណ្តូរប្រាក់គឺជារឿងស្តាប់រស់), (២) លាភការដែលធនាគារកណ្តាល និងធនាគារពាណិជ្ជកម្ម ទទួលបានពីរដ្ឋាភិបាលដោយសារការផ្តល់សេវាធនគារសម្រាប់រតនាគារ, (៣) ការផ្លាស់ប្តូរជាកាតព្វកិច្ចនូវទិន្នន័យ និងពត៌មាន រវាងស្ថាប័នរដ្ឋាភិបាល, និង (៤) មូលដ្ឋានការប្រាក់ដែលត្រូវបានបង់ដោយធនាគារ ឬធនាគារកណ្តាល ទៅអោយរតនាគារ ។ នៅក្នុងក្រសួងហិរញ្ញវត្ថុ ក៏តម្រូវអោយមានផងដែរនូវផ្លាស់ប្តូរញឹកញាប់នូវពត៌មាន រវាងនាយកដ្ឋានថវិកា, នាយកដ្ឋានរតនាគារ និងនាយកដ្ឋានបំណុល ស្តីអំពីបញ្ហាគ្រប់គ្រងសាច់ប្រាក់ ។ គ្រប់មុខងារទាំងអស់នេះ ទាមទារអោយបុគ្គលិកមាននូវសមត្ថភាពបច្ចេកទេសត្រឹមត្រូវ ។ បទបញ្ញត្តិច្បាស់លាស់សម្រាប់រចនាសម្ព័ន្ធនៃការគ្រប់គ្រងសាច់ប្រាក់ ក៏ជាតម្រូវការផងដែរ ។

**ការសម្របសម្រួលរវាងអ្នកគ្រប់គ្រងសាច់ប្រាក់, អ្នកគ្រប់គ្រងបំណុល និងអាជ្ញាធររូបិយវត្ថុ ។** អ្នកគ្រប់គ្រងសាច់ប្រាក់ ត្រូវការសហការជាគ្នាជាមួយអ្នកទទួលខុសត្រូវទៅលើការគ្រប់គ្រងបំណុល ជាពិសេសនៅក្នុងពេលដែលការគ្រប់គ្រងសាច់ប្រាក់ និងការគ្រប់គ្រងបំណុល ត្រូវបានធ្វើឡើងនៅក្នុងអង្គភាពដាច់ដោយឡែកពីគ្នា នៅក្នុងក្រសួងហិរញ្ញវត្ថុ ។ ដោយហេតុថា ការផ្តោតការយកចិត្តទុកដាក់របស់អ្នកគ្រប់គ្រងសាច់ប្រាក់សកម្ម មានរយៈពេលខ្លីខ្លាំងនោះ គេចាំបាច់ត្រូវសហការគ្នាជាមួយនឹងអ្នកគ្រប់គ្រងបំណុល ដែលទស្ស

នៈវិស័យរបស់គេមានរយៈពេលវែងជាង និងធ្វើកិច្ចសហការគ្នាជាមួយនឹងអាជ្ញាធររូបិយវត្ថុ (ធនាគារកណ្តាល) ។ នៅក្នុងបរិបទនេះ ការពិចារណាដូចខាងក្រោមនេះ មានសារៈសំខាន់៖

- **ទិសដៅនៃការគ្រប់គ្រងសាច់ប្រាក់ ការគ្រប់គ្រងបំណុលរដ្ឋាភិបាល អាចមានទំនាស់នឹងគ្នា** ។ នៅក្នុងពេលដែលកង្វល់ដ៏ធំរបស់អ្នកគ្រប់គ្រងសាច់ប្រាក់នៅក្នុងប្រទេសជឿនលឿន *ជាប្រចាំថ្ងៃ* គឺត្រូវធ្វើអតិបរមាកម្មចំណូលពីសមតុល្យសាច់ប្រាក់ដែលនៅទំនេរ និងកាត់បន្ថយអោយបានទាបបំផុតនូវការចំណាយទៅលើកម្ចីនោះ អ្នកគ្រប់គ្រងបំណុលរដ្ឋាភិបាលមានកង្វល់ថាត្រូវធ្វើយ៉ាងណាដើម្បីអោយផែនការកម្ចីរបស់រដ្ឋាភិបាល មានភាពត្រឹមត្រូវ ។ អ្នកគ្រប់គ្រងសាច់ប្រាក់ចូលរួមយ៉ាងសកម្មនៅក្នុងទីផ្សារហិរញ្ញវត្ថុ - ការបញ្ចេញសមតុល្យសាច់ប្រាក់នៅទំនេរបណ្តោះអាសន្នសម្រាប់រយៈពេលខ្លី ឬការខ្ចីសម្រាប់រយៈពេលខ្លី ។ អ្នកគ្រប់គ្រងបំណុលទាសម័យទំនើប ប្រកាសជាមុននូវកាលវិភាគទៀងទាត់សម្រាប់កម្ចីរបស់រដ្ឋាភិបាល ដែលមានសង្គតិភាពជាមួយនឹងផែនការប្របតិបត្តិគ្រប់គ្រងបំណុលប្រចាំឆ្នាំ [12] ។ តាមទស្សនៈរបស់អ្នកគ្រប់គ្រងសាច់ប្រាក់នីមួយ, ផែនការកម្ចីដែលត្រូវបានប្រកាសជាមុនអាចនាំអោយមានការខ្ចីច្រើនពេក ឬតិចពេក ដែលជាហេតុនាំអោយមានការបាត់បង់ប្រសិទ្ធិភាពនៅក្នុងការគ្រប់គ្រងសាច់ប្រាក់ប្រចាំថ្ងៃ ។ ទំនាស់ជាក់លាក់ទាំងនេះ អាចត្រូវបានដោះស្រាយ តាមរយៈការសម្របសម្រួលគ្នាជិតស្និទ្ធ និងការផ្លាស់ប្តូរពត៏មាន និងគោលបំណង រវាងអ្នកគ្រប់គ្រងសាច់ប្រាក់ និងអ្នកគ្រប់គ្រងបំណុល ដែលអាចនាំអោយមាននូវការកែប្រែទំហំនៃប័ណ្ណរតនាគារ ដែលត្រូវបានប្រកាសលក់ ។
- **ទាំងអ្នកគ្រប់គ្រងសាច់ប្រាក់រដ្ឋាភិបាល និងធនាគារកណ្តាល ត្រូវការនូវការព្យាករណ៍រយៈពេកខ្លីអំពីតម្រូវការសាច់ប្រាក់របស់រដ្ឋាភិបាល** ។ ជាមួយនឹងការគ្រប់គ្រងសាច់ប្រាក់សកម្ម, ក្រសួងហិរញ្ញវត្ថុ

---

[12] អ្នកគ្រប់គ្រងបំណុលធ្វើការខ្ចីដើម្បីផ្តល់ហិរញ្ញប្បទានដល់អោនភាពហិរញ្ញវត្ថុ ។ ជាបណ្តើរៗ គេធ្វើផែនការដោយអនុលោមទៅតាមក្របខ័ណ្ឌមេសម្រាប់ការគ្រប់គ្រងទ្រព្យ និងបំណុលរដ្ឋ (comprehensive government asset and liability management framework) (Wheeler, 2004) និងយោងទៅតាមយុទ្ធសាស្រ្តចេញប័ណ្ណបំណុលឥណទាន (credible bond issuance strategy) និងការគ្រប់គ្រងហានិភ័យប្រកបដោយការប្រុងប្រយ័ត្ន (IMF និង World Bank, ឆ្នាំ 2001 និង 2003) ។

ត្រូវចែករំលែកពត៌មានជាប្រចាំថ្ងៃស្តីអំពីការព្យាករណ៍របស់ខ្លួនអំពីតម្រូវការសាច់ប្រាក់របស់រដ្ឋាភិបាល ។ ការធ្វើរបៀបនេះមានសារៈប្រយោជន៍ ដើម្បីអោយធនាគារកណ្តាលធ្វើការប្រៀបធៀបនូវការព្យាករណ៍ទាំងនេះ ជាមួយនឹងការព្យាករណ៍របស់ធនាគារកណ្តាលខ្លួនឯង អំពីរូបិយវត្ថុភាព (liquidity-ភាពអាចប្តូរទៅជាសាច់ប្រាក់) នៅក្នុងធនាគារ ។ ដោយហេតុថា ការផ្ទេររូបិយវត្ថុភាព សុទ្ធ (net transfer of liquidity) រវាងវិស័យរដ្ឋាភិបាល និងវិស័យមិនមែនរដ្ឋាភិល ជារឿយៗគឺធាតុមួយដែលធំបំផុត និងមានការប្រែប្រួលបំផុត នៅក្នុងលំហាត់ព្យាករណ៍អំពីរូបិយវត្ថុភាព (liquidity) ក្នុងធនាគារកណ្តាលនោះ, ការព្យាករណ៍គប្បីត្រូវបានធ្វើឡើងអោយបានយ៉ាងត្រឹមត្រូវតាមដែលអាចធ្វើទៅបាន ។

**ការផ្ទេរបញ្ញើប្រាក់រដ្ឋាភិបាលចេញពីធនាការកណ្តាលទៅកាន់ធនាគារពាណិជ្ជកម្ម ធ្វើអោយប៉ះពាល់ដល់ការអនុវត្តន៍គោលនយោបាយរូបិយវត្ថុ** ។ ទោះបីជាប្រទេសមួយចំនួនតូច (ឧ. បារាំង) ប្រើប្រាស់តែធនាគារកណ្តាលប៉ុណ្ណោះ សម្រាប់ប្រតិបត្តិការធនាគាររដ្ឋាភិបាលក៏ដោយ, ប្រទេសភាគច្រើនបំផុតប្រើប្រាស់ធនាគារពាណិជ្ជកម្ម ។ ជារឿយៗផងដែរ ប្រទេសជឿនលឿនបានដាក់នូវបរិមាណដ៏ធំនៃអតិរិករូបិយវត្ថុភាព (liquidity) ទៅក្នុងទីផ្សារ, ឧទាហរណ៍តាមរយៈ ប្រតិបត្តិការទិញហើយលក់វិញ (reverse repo operations) ឬការដាក់បញ្ញើដែលមានកំណត់រយៈពេលជាក់លាក់ (term deposits) នៅក្នុងធនាគារពាណិជ្ជកម្ម ។ ការផ្ទេរមូលនិធិរដ្ឋាភិបាលចេញពីធនាគារកណ្តាលទៅកាន់ទីផ្សារហិរញ្ញវត្ថុ (ឬផ្ទុយមកវិញ) ធ្វើអោយប៉ះពាល់ទៅដល់រូបិយវត្ថុភាពរបស់ធនាគារ (bank liquidity) និងប៉ះពាល់ ដល់អត្រាការប្រាក់ផងដែរ ។ អាស្រ័យហេតុនេះ អ្នកគ្រប់គ្រងសាច់ប្រាក់រដ្ឋាភិបាល ត្រូវធ្វើកិច្ចសហការគ្នាជាមួយនឹងធនាគារកណ្តាល, ជាពិសេសពាក់ព័ន្ធជាមួយនឹងគ្រប់ការផ្ទេរទាំងអស់នៃមូលនិធិរដ្ឋាភិបាល ដែលមិនត្រូវបានឬំពឹងទុក ។ ឧទាហរណ៍, នៅក្នុងសហរដ្ឋអាមេរិក មានការប្រជុំតាមទូរស័ព្ទជារៀងរាល់ថ្ងៃ រវាងរតនាគារសហរដ្ឋ និងធនាគារបំរុងសហព័ន្ធ ដែលនៅក្នុងការប្រជុំនោះ ការផ្ទេរមូលនិធិសហព័ន្ធដែលត្រូវបានស្នើឡើងត្រូវបានបង្ហាញ ។

## III. ការធ្វើផែនការ និងការព្យាករណ៍សាច់ប្រាក់

**ដើម្បីអោយការគ្រប់គ្រងសាច់ប្រាក់មានប្រសិទ្ធភាពនោះ, រតនាគារត្រូវបង្កើតឡើងនូវការប៉ាន់ប្រមាណរយៈពេលខ្លីត្រឹមត្រូវ និងទាន់ពេលវេលា អំពីលំហូរចូល និងលំហូរចេញនៃសាច់ប្រាក់** ។ លំហូរសាច់ប្រាក់ដែលត្រូវធ្វើការប៉ាន់ប្រមាណរួមបញ្ចូលនូវចំណូល និងការបង់ប្រាក់ (មានន័យថា អ្វីៗដែលចូលរួមចំណែកអោយមានសមតុល្យហិរញ្ញវត្ថុ - អោនភាព ឬអតិរេក) និងប្រតិបត្តិការហិរញ្ញប្បទាន [(មានន័យថា ការផ្លាស់ប្តូរទ្រព្យហិរញ្ញវត្ថុ និងបំណុលសុទ្ធ (net financial assets and liabilities) ដែលផ្តល់ហិរញ្ញប្បទានដល់សមតុល្យហិរញ្ញវត្ថុ] ។ ទិសដៅដ៏សំខាន់ គឺការប៉ាន់ប្រមាណជាមុនអំពីតម្រូវការសាច់ប្រាក់របស់រដ្ឋាភិបាល និងដើម្បីធានាថា ការបង់ប្រាក់ត្រូវបានធ្វើឡើងទាន់ពេលវេលា ។

**ធាតុសំខាន់ៗនៃក្របខ័ណ្ឌព្យាករណ៍សាច់ប្រាក់** ។ ធាតុទាំងនេះ តម្រូវអោយ៖

**មាននូវក្របខ័ណ្ឌពេញលេញ** ដែលរួមបញ្ចូលនូវរាល់ហូរចូលទាំងអស់នៃធនធានសាច់ប្រាក់រដ្ឋាភិបាល និងផ្តល់ជាក្របខ័ណ្ឌសម្រាប់ការធ្វើផែនការអំពីការទូទាត់បំណុលសាច់ប្រាក់រយៈពេលខ្លី និងរយៈពេលវែង ។ ក្របខ័ណ្ឌបែបនេះទាមទារអោយមាននូវប្រព័ន្ធគ្រប់គ្រងពត៌មានថវិកា ដែលមានលក្ខណៈពេញលេញ, មានទិន្នន័យទាន់ពេលវេលា, ត្រឹមត្រូវ និងយកជាការបាន ។

**ធ្វើសង្គតិភាពរវាងការធ្វើផែនការចំណាយ និងការចំណាយសាច់ប្រាក់ជាក់ស្តែង** ដោយក្រសួងស្ថាប័ន ដើម្បីកុំអោយមាននូវការអាក់ខានក្នុងការចំណាយនៅក្នុងពេលអនុវត្តន៍ថវិកា ឬការជំពាក់ការទូទាត់ណាមួយឡើយ ។ ប្រការនេះទាមទារអោយក្រសួងដែលពាក់ព័ន្ធធ្វើផែនការចំណាយរបស់ខ្លួនប្រកបដោយភាពប្រុងប្រយ័ត្នដោយមានកិច្ចសហការគ្នាជាមួយនឹងក្រសួងហិរញ្ញវត្ថុ ដែលក្រោយមកត្រូវឆ្លើយតបទៅនឹងតម្រូវការសាច់ប្រាក់របស់ក្រសួងស្ថាប័ន ។

**ផ្តល់ការលើកទឹកចិត្តដល់ស្ថាប័នថវិកាដើម្បីអោយគេផ្តល់នូវផែនការសាច់ប្រាក់ដែលមានភាពប្រាជ្ញប្រជា** ។ ជានិច្ចកាល គេតែងតែមាននូវភាពមិនច្បាស់លាស់ នៅក្នុងការព្យាករណ៍: ផែនការក្នុងឆ្នាំរបស់ស្ថាប័ន អាចមានការប្រែប្រួល, កិច្ចសន្យាមិនត្រូវបានចុះហត្ថលេខាក្នុងពេលវេលាតាមការរំពឹងទុក, វិក័យប័ត្រមិនត្រូវបានទទួលតាមការគិតជាមុន ។ល។ ប៉ុន្តែ នៅក្នុងពេលផ្លាស់ប្តូរចេញពីប្រព័ន្ធដាក់កំហិតសាច់ប្រាក់ (cash

rationing system) ទៅកាន់ការគ្រប់គ្រងសាច់ប្រាក់ដែលកាន់តែមានភាពសកម្មនោះ, អភិក្រមលើកទឹកចិត្ត និងដាក់ទណ្ឌកម្ម (a carrot and stick approach) អាចជាប្រការចាំបាច់ ។ ស្ថាប័នថវិកា ដែលផ្តល់នូវការព្យាករណ៍ត្រឹមត្រូវអំពីតម្រូវការសាច់សាច់ប្រាក់នោះ អាចត្រូវបានផ្តល់អោយនូវស្វ័យភាពកាន់តែច្រើនឡើង នៅក្នុងការគ្រប់គ្រងការចំណាយនៃចំណាកថវិការបស់គេ [13]។

**ការព្យាករណ៍គឺជាលំហាត់បច្ចេកទេស ដែលទាមទារអោយមាននូវកិច្ចសហការគ្នា រវាងភាគីទាំងអស់ដែលពាក់ព័ន្ធ** ។ ធាតុដែលគេចង់បាន សម្រាប់ការរៀបចំផែនការសាច់ប្រាក់រយៈពេលខ្លី រួមមាន៖

- **សង្គតិភាពជាមួយនឹងការព្យាករណ៍ថវិកាប្រចាំឆ្នាំ** ។ ចំណុចចាប់ផ្តើមសម្រាប់ផែការសាច់ប្រាក់ក្នុងឆ្នាំ គឺសាច់ប្រាក់ដែលគេត្រូវការដើម្បីអនុវត្តថវិកាប្រចាំឆ្នាំ ដែលត្រូវបានអនុម័តិដោយសភា ។ ការធ្វើឬប្បន្នភាពដោយទៀងទាត់នូវការព្យាករណ៍អំពីលំហូរសាច់ប្រាក់ប្រចាំថ្ងៃ, ប្រចាំសប្តាហ៍ និងប្រចាំខែ នៅតែបន្តមានបញ្ហាដោយសារការព្យាករណ៍ថវិកាប្រចាំឆ្នាំ (ដោយផ្អែកលើមូលដ្ឋានសាច់ប្រាក់) ។

- **ការផ្តោតទៅលើលំហូរចូល និងលំហូរចេញសំខាន់ៗ** ។ ការផ្តោតការយកចិត្តទុកដាក់គប្បីត្រូវបាធ្វើឡើង ដើម្បីធានាថា ការព្យាករណ៍សម្រាប់ចំណូលពន្ធសំខាន់ៗ និងចំណូលដទៃទៀត និងសម្រាប់ការចំណាយសំខាន់បំផុត កាន់តែមានភាពប្រកដប្រជា តាមដែលអាចធ្វើទៅបាន ។ ការព្យាករណ៍អំពីចំណូល និងការចំណាយតូចតាច អាចត្រូវបានសន្មត់ថាដើរតាមគន្លងនៃគំរូធម្មតា ។

- **ការកំណត់គំរូអតីតកាលសម្រាប់លំហូរចូល និងលំហូរចេញជាក់លាក់** ។ សម្រាប់ប្រការនេះ, មូលដ្ឋានទិន្នពត៍មាន គប្បីត្រូវបានបង្កើតឡើង ដោយប្រើប្រាស់ទិន្នន័យអតីតកាលយូរអង្វែង ដែលមាននៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ។ ម៉ូឌុលព្យាករណ៍សាច់ប្រាក់ ដែលប្រើប្រាស់នូវទិន្នន័យ

---

[13] ការលើកទឹកចិត្តនេះ ត្រូវបានធ្វើឡើងដោយចំហនៅក្នុងចក្រភពអង់គ្លេស ។ ក្រសួងចំណាយដែលមានប្រវត្តិព្យាករណ៍មិនបានល្អ ទទួលនូវការដាក់ពិន័យដោយការកាត់បន្ថយថវិកាចេញពីចំណាយនាឆ្នាំបន្ទាប់របស់ខ្លួន ត្រូវបានផ្តល់ទៅអោយក្រសួងស្ថាប័នណាដែលមានប្រវត្តិព្យាករណ៍បានត្រឹមត្រូវជាង ។ ពិន័យគឺផ្អែកទៅលើចំណាយបន្ថែម ដែលអ្នកគ្រប់គ្រងសាច់ប្រាក់ប្រឈម ក្នុងពេលដែលគេត្រូវធ្វើការខ្ចី ឬអោយគេខ្ចី បន្ទាន់ ដោយសារតែកំហុសនៅក្នុងការព្យាកណ៍ ។

គណនេយ្យអតីតកាលយូរអង្វែង អាចមានមូលដ្ឋានទិន្នន័យដាច់ដោយឡែកពីគ្នា ។ ភាពទាន់ពេលវេលា និងសមត្ថភាពបង្កើតឡើងនូវសេណារីយ៉ូ គឺជាកត្តាដ៏សំខាន់ ។

- **ការកំណត់ពេលវេលានៃលំហូរសំខាន់ៗ** ។ លំហូរធំៗមួយចំនួនមានពេលវេលាជាក់លាក់ និងអាចត្រូវបានកំណត់ជាមុន ។ លំហូរទាំងនេះ អាចរួមបញ្ចូលៈ ការបង់ពន្ធដោយបណ្តាក្រុមហ៊ុនធំៗបំផុត, ជំនួយឥតសំណងរបស់ម្ចាស់ជំនួយបរទេស, ការចេញប័ណ្ណបំណុល (bond issuances) និងការរលោះ, ការបើកប្រាក់ខែ, ការប្រាក់សម្រាប់កម្ចីរដ្ឋាភិបាល, ការចំណាយប្រាក់ទៅលើគម្រោងសាធារណៈសំខាន់ៗ, ការផ្ទេរទៅកាន់ថ្នាក់ក្រោមជាតិ, ប្រាក់សុខុមាលភាពសង្គម ឬប្រាក់សោធននិវត្តន៍ ។

- **បង្កើតការផ្សារភ្ជាប់រវាងរតនាគារ និងស្ថាប័នប្រមូលចំណូល សម្រាប់ពេលវេលាសមស្របនៃលំហូរចូល** ។ នៅក្នុងពេលដែលគេមានជំរើសពេលវេលាសម្រាប់លំហូរចូលនោះ, ប្រការដ៏សំខាន់នោះគឺថារតនាគាធ្វើការពិភាក្សាជាមួយស្ថាប័នពន្ធ និងស្ថាប័នគយ ។ ដើម្បីទទួលបាននូវសមតុល្យរវាងលំហូរចេញ និងលំហូរចូល រតនាគារអាចស្នើទៅស្ថាប័នប្រមូលពន្ធថា កាលបរិច្ឆេទនៃការបង់ពន្ធគប្បីត្រូវបានធ្វើឡើងនៅក្នុងពាក់កណ្តាលខែ ប្រសិនបើតាមធម្មតាគេមានលំហូរចេញសាច់ប្រាក់នៅក្នុងពាក់កណ្តាលខែនោះ ។ ដូចគ្នានេះដែរ សម្រាប់ការលក់ម្តងម្កាលនៃទ្រព្យមូលធន (ឧ. ចំណូលមកពីការធ្វើឯកជនូបនីយកម្ម) រតនាគារនឹងត្រូវព្យាយាមធានាថាចំណូលពីការលក់បែបនេះ ត្រូវបានដាក់នៅក្នុងគណនីរតនាគារទោល នៅក្នុងថ្ងៃដែលលំហូរចេញកើតឡើង ។

- **ការបង្កត់ឡើងនូវទំនាក់ទំនងការងារ រវាងក្រសួងហិរញ្ញវត្ថុ និងក្រសួងស្ថាប័ន** ។ រតនាគារត្រូវការទទួលបាននូវពត៍មានពីស្ថាប័ន ដែលនៅជិតបំផុតទៅនឹងប្រតិបត្តិការ ។ ទីស្តីការនៃក្រសួងចំណាយគប្បីអាចទទួលបាននូវពត៍មានអង្គភាពថវិកាថ្នាក់ក្រោមរបស់ខ្លួន ។ អង្គភាពគ្រប់គ្រងសាច់ប្រាក់របស់ក្រសួងហិរញ្ញវត្ថុ អាចចាត់តាំងបុគ្គលិករបស់ខ្លួនអោយធ្វើការទំនាក់ទំនងជាមួយនឹងស្ថាប័នចំណាយ ស្តីអំពីករព្យាករណ៍អំពីលំហូរសាច់ប្រាករបស់គេ ។ រាល់ការប្រែប្រួលទាំងនៅក្នុងការព្យាករណ៍, ជាពិសេសប្រសិនបើមានការផ្លាសប្តូរធំៗ, គប្បីត្រូវបានផ្តល់ដំណឹងភ្លាមៗ ទៅកាន់អ្នកគ្រប់គ្រងសាច់

ប្រាក់ [14] ដើម្បីអោយពួកគេអាចធ្វើបច្ចុប្បន្នភាពអំពីការព្យាករណ៍លំហូរសាច់ប្រាក់សរុប ។ ការចែករំលែកពត៌មានភ្លាមៗតែម្តង មានសារៈប្រយោជន៍បំផុត ។

- **ការធ្វើការកំណត់អំពីតម្រូវការសាច់ប្រាក់តាមរយៈការធានាចំណាយ** ។ ក្រសួង និងស្ថាប័ន គឺជាអ្នកដែលអាចធ្វើការព្យាករណ៍បានល្អបំផុត អំពីនិន្នាការនៃការចំណាយរបស់គេ (និងចំណូលដែលគេប្រមូល) ។ ក្រសួងទាំងនោះគឺជាអ្នកចុះកិច្ចសន្យា ដែលក្រោយមកតម្រូវអោយមានការទូទាត់វិក័យប័ត្រ ។ ការយឺតយ៉ាវជាធម្មតារវាងពេលកត់ត្រាការធានាចំណាយ និងការទូទាត់ចំណាយស ម្រាប់ទំនិញ ឬសេវា ត្រូវបានដឹងដោយក្រសួងចំណាយ ។ ប្រការដ៏សំខាន់នោះ គឺថាគេត្រូវធ្វើការធានាថា ក្រសួង និងស្ថាប័ន ធ្វើការរៀបចំនូវផែនការហិរញ្ញវត្ថុរបស់គេៈ ទាំងកាលវិភាគនៃការធានាចំណាយ និងលំហូរចេញនៃសាច់ប្រាក់ដែលអាចកើតមានឡើង ។ នៅក្នុងពេលដែលព្រំដែននៃការចំណាយត្រូវបានបង្កើតឡើងហើយ, ឧទាហរណ៍៖ ប្រចាំត្រីមាស, នោះការទស្សន៍ទាយអំពីលំហូរចេញនៃសាច់ប្រាក់ ត្រូវបានកែលំអ ។
- **ការបែងចែកនូវការចែករំលែកពត៌មាន អោយដាច់ស្រឡះពីការត្រួតពិនិត្យចំណាយ** ។ ក្រសួង អាចទាមទារអោយមានការធានាថា ពត៌មានដែលត្រូវបានផ្តល់ទៅអោយរតនាគារនោះ នឹងត្រូវបានប្រើប្រាស់តែសម្រាប់គោលបំណងគ្រប់គ្រងសាច់ប្រាក់តែប៉ុណ្ណោះ មិនមែនសម្រាប់ការត្រួតពិនិត្យចំណាយទេ ។ ប្រសិនបើវាមិនច្បាស់លាស់ទេនោះ ក្រសួងអាចមានការស្ទាក់ស្ទើរក្នុងផ្តល់អោយនូវកាន់ប្រមាណមិនលំអៀងអំពីតម្រូវការសាច់ប្រាក់ ឬផ្ទុយមកវិញមិនផ្តល់ពត៌មាន រួមទាំងពត៌មានស្តីអំពីចំណូលដែលគេទទួលបាន តាមប្រតិបត្តិការផ្ទាល់ខ្លួនរបស់គេ និងដាក់នៅក្នុងគណនីរតនាគារ ដែលមិនស្ថិតនៅក្រោមការមើខុសត្រូវរបស់រតនាគារ ។

---

[14] ឧទាហរណ៍: នៅក្នុងប្រទេសបារាំង AFT ទាមទារអោយរដ្ឋាភិបាលថ្នាក់មូលដ្ឋានផ្តល់ដំណឹងមុនមួយថ្ងៃ នៅត្រឹមម៉ោង ៤ល្ងាច, អំពីប្រតិបត្តិការដែលមានតម្លៃធំ - ប្រតិបត្តិការដែលមានតម្លៃលើស ១ពាន់លានអឺរ៉ូ (សូមមើល AFT, ឆ្នាំ 2006) ។ នៅក្នុងសហរដ្ឋអាមេរិក, តរនាគារសហរដ្ឋអាមេរិក ទាមទារថា ការចំណាយ ឬចំណូលដែលមានតម្លៃលើសពី ៥០០ (ឬ ៥០) លានដុល្លា ត្រូវបានផ្តល់ដំណឹងជាមុន ៥ (ឬ ២) ថ្ងៃធ្វើការ (សូមមើល Rascoe, ឆ្នាំ 2007) ។

**ការព្យាករណ៍អំពីផែនការសាច់ប្រាក់ គប្បីត្រូវបានធ្វើបច្ចុប្បន្នភាពដោយទៀងទាត់** ។ នៅក្នុងពេលអនាគត ការព្យាករណ៍បែបបនេះ គប្បីត្រូវបានសម្រិតសម្រាំង ។ ក្របខ័ណ្ឌមេសម្រាប់ផែនការសាច់ប្រាក់ដំបូង ដោយផ្អែកទៅលើការព្យាករណ៍ប្រចាំខែ ស្របទៅតាមថវិកាប្រចាំឆ្នាំ ត្រូវបានពង្រៀងនៅក្នុងតារាង ១ ។ នៅក្នុងប្រទេសជឿនលឿន ការព្យាករណ៍ប្រចាំថ្ងៃអំពីលំហូរសាច់ប្រាក់ ត្រូវបានរៀបចំយ៉ាងហោចណាស់ បីខែជាមុន ហើយ ការព្យាករណ៍បែបនេះ ត្រូវបានរំកិលទៅមុខ ជារឿយៗ ។ នៅក្នុងប្រទេសដែលមានការ រីកចំរើនតិច, ការព្យាករណ៍ប្រចាំសប្តាហ៍ ឬ ១០ ថ្ងៃម្តង ជារឿយៗត្រូវបានរៀបចំឡើងមុនគេបង្អស់ [15]។ ខ្ទង់ចំណាយធំៗបំផុត ត្រូវបានបំបែកលំអិត ដោយមានការព្យាករណ៍លំអិត ទៅតាមស្ថាប័នប្រមូលចំណូល ឬទៅតាមក្រសួងចំណាយ និងការបង្ហាញជាក់លាក់អំពីថ្ងៃពិតប្រាកដ ដែលចំណូលធំៗ ត្រូវបានទទួល ឬការ ចំណាយធំៗត្រូវទូទាត់ ។

**ភាពប្រចាំនៃការធ្វើបច្ចុប្បន្នភាព គប្បីមានលក្ខណៈជាប្រចាំថ្ងៃ នៅក្នុងពេលអនាគត** ។ ដោយហេតុថា ការ គ្រប់គ្រងសាច់ប្រាក់កាន់តែមានភាពសកម្មនោះ អ្នកគ្រប់គ្រងសាច់ប្រាក់ នឹងត្រូវព្យាយាមធ្វើអប្បបរមាកម្ម សមតុល្យសាច់ប្រាក់ដែលនៅទំនេរ និងអាចធ្វើការខ្ចីគេ ដើម្បីដោះស្រាយកង្វះខាតសាច់ប្រាក់បណ្តោះ អាសន្នរយៈពេលខ្លី ។ ការធ្វើបច្ចុប្បន្នភាពផែនការសាច់ប្រាក់រំកិលទៅមុខ នៅក្នុងអនាគត គប្បីត្រូវបានធ្វើ ប្រចាំថ្ងៃ ។ សម្រាប់បណ្តាប្រទេសជឿនលឿនភាគច្រើនបំផុត ការគ្រប់គ្រងសាច់ប្រាក់ប្រចាំថ្ងៃ ត្រូវបានអនុ វត្ត ។

**អ្នកគ្រប់គ្រងសាច់ប្រាក់សម័យទំនើប ធ្វើការដោះស្រាយនូវអោនភាព ឬអតិរេកសាច់ប្រាក់បណ្តោះអាសន្ន ដោយផ្អែកជាសំខាន់ទៅលើកម្ចីរយៈពេលខ្លីក្នុងទីផ្សារហិរញ្ញវត្ថុ** ។ នៅក្នុងឧទាហរណ៍សម្មតិកម្មស្តីអំពីថវិកា ដែលមានលំនឹង និងចំណូលប្រមូលពេលក្រោយ (back-loaded revenues) ដែលត្រូវបានបង្ហាញនៅក្នុង តារាង ១, អ្នកគ្រប់គ្រងសាច់ប្រាក់រដ្ឋាភិបាល នឹងត្រូវការខ្ចីគេនៅដើមឆ្នាំដើម្បីចៀសវាងនូវសមតុល្យ អវិជ្ជមាន ដែលត្រូវបានព្យាករណ៍សម្រាប់រយៈពេល ៧ខែ ក្នុងរយៈពេល ៩ខែដំបូងនៃឆ្នាំ ថវិកា (សូមមើល

[15] ឧទាហរណ៍: Burkina Faso រៀបចណាផែនការសាច់ប្រាក់ប្រចាំខែ ដែលត្រូវបានអនុម័តិដោយគណកម្មការជាន់ ខ្ពស់ និងការព្យាករណ៍ រយៈពេល ១០ នៅក្នុងផែនការសាច់ប្រាក់ប្រចាំខែ ដែលត្រូវបានគ្រប់គ្រង ដោយនាយកដ្ឋាន រតនាគារនៃក្រសួងហិរញ្ញវត្ថុ ។

បន្ទាត់ចុងក្រោយនៃផ្នែកខាងក្រោមនៅក្នុងតារាង ១) ។ នៅក្នុងឧទាហរណ៍នេះ (ដែលសម្មត់ថាគ្មានការចេញប័ណ្ណបំណុល) កម្ចីទាំងអស់នៅក្នុងឆ្នាំ នឹងត្រូវសងវិញអោយអស់នៅត្រឹមចុងឆ្នាំ ។

**នៅក្នុងប្រទេសដែលមានចំណូលទាប ប្រសិនបើមានកង្វះខាតសាច់ប្រាក់ ហើយកម្ចីរយៈពេលខ្លីមិនអាចធ្វើទៅបាននោះ វិធានការចម្រុះសម្រាប់ដោះស្រាយកង្វះខាតបែបនេះ គប្បីត្រូវបានគិតពិចារណា** ។ វិធានការណ៍ទាំងនេះរួមមាន: បង្កើនការប្រមូលចំណូល, ពន្យារការចំណាយ (ក្នុងដំណាក់កាលនៃការធានាចំណាយ ជាជាង ក្នុងដំណាក់កាលសាច់ប្រាក់ ពីព្រោះថា ការពន្យារនូវទូទាត់សាច់ប្រាក់ នាំអោយមាននូវការជំពាក់សាច់ប្រាក់) និងការធ្វើវិសោធនកម្មថវិកាប្រចាំឆ្នាំ ប្រសិនបើការខ្វះខាតចំណូល កើតឡើងដោយសារការព្យាករណ៍ចំណូលថវិកាប្រកបដោយភាពសុទិដ្ឋិនិយមនោះ ។

**អង្គភាពព្យាករណ៍សាច់ប្រាក់** ។ អង្គភាពគ្រប់គ្រងសាច់ប្រាក់ត្រូវធ្វើការចាត់តាំងបុគ្គលិកមួយចំនួនអោយទទួលខុសត្រូវលើការធ្វើបច្ចុប្បន្នភាពការព្យាករណ៍បច្ចេកទេស ។ ក្រុមមន្ត្រីទាំងបែបនេះ តាមធម្មតាមានទំហំតូច (ប្រហែលជា ៣-៥នាក់ ដែលធ្វើការពេញម៉ោង) ។

**តម្រូវពត៌មានវិទ្យា (IT)** ។ កាលណាពត៌មានកាន់តែមានភាពស្មុគ្រស្មាញនោះ គេក៏ត្រូវការមាននូវប្រព័ន្ធពត៌មានដែលមានគុណភាពខ្ពស់ផងដែរ ។ ប្រពន្ធពត៌មានវិទ្យាដែលមានគុណភាពខ្ពស់ គឺជាតម្រូវការចាំបាច់ដើម្បីជួយសម្រួលដល់ការរៀបចំ និងធ្វើបច្ចុប្បន្នកម្មនូវការព្យាករណ៍សាច់ប្រាក់រយៈពេលខ្លី និងការរក្សានូវមូលដ្ឋានទិន្នន័យស្តីអំពីនិន្នាការលំហូរសាច់ប្រាក់ ។ ជម្រើសមួយ គឺការដាក់បញ្ចូលនូវម៉ូឌុលព្យាករណ៍សាច់ប្រាក់ដែលសមស្របបំផុតជាផ្នែកមួយនៃប្រព័ន្ធពត៌មានស្តីអំពីការគ្រប់គ្រងហិរញ្ញវត្ថុរួមបញ្ចូលគ្នា (IFMIS) នៅក្នុងពេលដែលម៉ូឌុលគណនេយ្យនៃ IFMIS នឹងផ្តល់នូវទិន្នន័យស្តីអំពីលំហូរចូល និងលំហូរចេញ ។ នៅក្នុងបណ្តាប្រទេសដែលមានការធ្វើវិមជ្ឈការយ៉ាងច្រើននូវការគ្រប់គ្រងហិរញ្ញវត្ថុទៅអោយស្ថាប័នចំណាយ, ជាមួយនឹងការព្យាករណ៍រយៈពេលខ្លីដែលត្រូវបានធ្វើបច្ចុប្បន្នយ៉ាងទៀងទាត់ដោយក្រសួងនៅក្នុងប្រព័ន្ធ ITរបស់គេនោះ គេត្រូវធានាថាការព្យាករណ៍របស់បណ្តាក្រសួងទាំងនោះ ត្រូវបានបញ្ជូនទៅកាន់ IFMIS របស់អ្នកគ្រប់គ្រងសាច់ប្រាក់ថ្នាក់កណ្តាល និងត្រូវបានបូកសរុបផ្ទៀងផ្ទាត់ ។

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | /ខែ/ឆ្នាំ | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| រូថ | | តិ | មករា | កុម្ភៈ | មិនា | សោ | ឧសភា | ទា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
| | | Proj. | Proj/ Ac | Proj/ Ac | Proj/ Ac | Proj/ Ac | Proj/ Ac | Proj/ Ac | Proj/ Ac | Proj/ Ac | Proj/ Ac | Proj/ Ac | Proj/ Ac | Proj/ Ac | **ជាក់ស្តែង** |
| 21000 | បពន្ធ | 200 | 10 | 10 | 10 | 10 | 10 | 30 | 10 | 10 | 10 | 10 | 30 | 50 | **200** |
| 22000 | ទានសង្គម | 60 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | **60** |
| 24000 | បពីទ្រព្យ | 20 | 0 | 0 | 5 | 0 | 0 | 5 | 0 | 0 | 5 | 0 | 0 | 5 | **20** |
| 25000 | | 30 | 2 | 2 | 3 | 2 | 3 | 2 | 3 | 3 | 3 | 3 | 2 | 2 | **30** |
| 26000 | | 50 | 0 | 0 | 0 | 0 | 0 | 20 | 0 | 0 | 0 | 0 | 0 | 30 | **50** |
| 27000 | ន្ទូបនីយកម្ម) | 20 | 2 | 1 | 2 | 3 | 2 | 1 | 2 | 1 | 2 | 1 | 2 | 1 | **20** |
| 28000 | | 40 | 0 | 0 | 10 | 0 | 0 | 10 | 0 | 0 | 0 | 10 | 0 | 10 | **40** |
| 29000 | | 80 | 0 | 0 | 20 | 0 | 0 | 0 | 20 | 0 | 0 | 20 | 0 | 20 | **80** |
| | | **500** | **19** | **18** | **55** | **20** | **20** | **73** | **40** | **19** | **25** | **49** | **39** | **123** | **500** |
| 11000 | ខែ | 186 | 15 | 15 | 15 | 15 | 15 | 15 | 16 | 16 | 16 | 16 | 16 | 16 | **186** |
| 12000 | ដើរការ | 60 | 4 | 4 | 4 | 5 | 5 | 5 | 6 | 6 | 6 | 5 | 5 | 5 | **60** |
| 13000 | | 30 | 0 | 0 | 0 | 10 | 0 | 0 | 10 | 0 | 0 | 0 | 0 | 10 | **30** |
| 14000 | | 70 | 5 | 5 | 12 | 5 | 12 | 12 | 2 | 7 | 5 | 5 | 5 | 5 | **80** |
| 16000 | | 60 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | **60** |
| 18000 | | 94 | 0 | 0 | 20 | 0 | 0 | 20 | 0 | 0 | 20 | 0 | 0 | 24 | **84** |
| | | **500** | **29** | **29** | **56** | **40** | **37** | **57** | **39** | **34** | **52** | **31** | **31** | **65** | **500** |
| | | **0** | **-10** | **-11** | **-1** | **-20** | **-17** | **16** | **1** | **-15** | **-27** | **18** | **8** | **58** | **0** |
| | | | | | | | | | | | | | | | |
| | ព្យាករណ៍ | | | | | | | | | | | | | | |
| | | | **20** | **10** | **-1** | **-2** | **-22** | **-39** | **-23** | **-22** | **-37** | **-64** | **-46** | **-38** | **20** |
| | | | **-10** | **-11** | **-1** | **-20** | **-17** | **16** | **1** | **-15** | **-27** | **18** | **8** | **58** | **0** |
| | | | **10** | **-1** | **-2** | **-22** | **-39** | **-23** | **-22** | **-37** | **-64** | **-46** | **-38** | **20** | **20** |

## IV. ការប្រឈមមុខក្នុងការគ្រប់គ្រងសាច់ប្រាក់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងមានចំណូលទាប

**ការបង្កើតឡើងនូវការគ្រប់គ្រងសាច់ប្រាក់ដែលមានប្រសិទ្ធភាព គឺការលំបាកនៅក្នុងបណ្តាប្រទេសដែលមានចំណូលមធ្យម និងចំណូលទាប** ។ ឧបសគ្គដ៏សំខាន់មួយគឺអវត្តមាននៃប្រព័ន្ធធនាគារទំនើប ដែលផ្តល់លទ្ធភាពអោយរតនាគារធ្វើការកាត់បន្ថយជាប្រចាំថ្ងៃនូវការយឺតយ៉ាវក្នុងការផ្ទេរចំណូល និងការទទាត់ចំណាយ ។ ឧបសគ្គមួយនេះ និងកង្វះខាតដ៏ទៃទៀត ត្រូវបានលើកឡើងដូចខាងក្រោម៖

- **ប្រព័ន្ធធនាគារមិនសូវរីកចំរើន ឬមិនត្រូវបានប្រើប្រាស់អោយអស់លទ្ធភាព** ។ ដើម្បីធ្វើការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកនោះ រតនាគារត្រូវតែរង់ចាំដំណើរតំឡើងបណ្តាញកុំព្យូទ័រអេឡិចត្រូនិកនៅទូទាំងប្រទេស នៅក្នុង និងរវាងធនាគារពាណិជ្ជកម្ម, ធនាគារកណ្តាល និងរតនាគារ/ក្រសួងហិរញ្ញវត្ថុ ។ អ្នកគ្រប់គ្រងសាច់ប្រាក់ ត្រូវដឹងអំពីកិច្ចប្រឹងប្រែងរបស់ធនាគារពាណិជ្ជកម្មក្នុងការធ្វើទំនើបកម្មខ្លួន ដើម្បីត្រៀមខ្លួនធ្វើកិច្ចសន្យាជាមួយនឹងធនាគារទាំងនោះ អោយផ្តល់សេវាធនាគារដល់រតនាគារ ។ ទោះបីជាជានិច្ចកាលធនាគារកណ្តាលគប្បីត្រូវបានប្រើប្រាស់ធ្វើជាអ្នកថែរក្សាគណនី (custodian) ប្រតិបត្តិមេរបស់គណនីទោលរតនាគារក៏ដោយ, គណនីបណ្តោះអាសន្នដែលមាននៅក្នុងសាខារបស់ធនាគារពាណិជ្ជកម្ម ដែលត្រូវបានជ្រើសរើសឡើងដោយការដេញថ្លៃដែលមានការប្រកួតប្រជែងនោះ, ផ្តល់នូវលទ្ធភាពដ៏ល្អបំផុតសម្រាប់ទទួលចំណូលពីអ្នកបង់ពន្ធ និងសម្រាប់ការទូទាត់ប្រាក់ទៅអោយអ្នកផ្គត់ផ្គង់របស់រដ្ឋាភិបាល (ជាថ្មីម្តងទៀតតាមរយៈប្រព័ន្ធអេឡិចត្រូនិក), ជាពិសេសសម្រាប់ប្រតិបត្តិការ ដែលស្ថិតនៅខាងក្រៅរដ្ឋធានី ដែលរតនាគារ និងធនគារកណ្តាល ស្ថិតនៅទីនោះ ។

- **ការទូទាត់ត្រូវបានធ្វើឡើងជាក្រដាសប្រាក់** ។ នៅក្នុងបណ្តាប្រទេសចំណូលទាប, រតនាគារនៅតែចាត់សាច់ប្រាក់ជាក់ស្តែង - ជាពិសេសនៅខាងក្រៅទីក្រុងធំៗ - ទាំងសម្រាប់ការប្រមូលចំណូល និងសម្រាប់ការទូទាត់ចំណាយ, រួមទាំងប្រាក់ខែមន្ត្រីរាជការ ។ សាច់ប្រាក់ដែលត្រូវបានរក្សានៅក្នុងទូដែក មិនផ្តល់នូវផលចំណេញទេ និងមិនត្រូវបានគ្រប់គ្រងនៅក្នុងគណនីទោលរតនាគារទេ

ហើយអាស្រ័យហេតុនេះ ការអនុវត្តន៍បែបនេះផ្ទុយទៅនឹងគោលការណ៍នៃការគ្រប់គ្រងល្អនូវសាច់ប្រាក់ ដែលប្រមូលផ្តុំនូវរូបិយវត្ថុភាព (liquidity) និងធ្វើអតិបរមាកម្មចំណូលចេញពីអតិរេកសាច់បណ្តោះអាសន្ន ។

- **អដ្ឋិភាពនៃពហុគណនីធនាគាររដ្ឋាភិបាល** ។ ក្រសួងហិរញ្ញវត្ថុ មិនអាចធ្វើការត្រួតពិនិត្យបានពេញលេញ ទៅលើគណនីធនាគាររដ្ឋាភិបាលទាំងអស់នោះទេ៖ គណនីដ៏ទៃទៀត អាចត្រូវបានបើកដោយអាជ្ញាធរដែលនៅខាងក្រៅក្រសួងហរិញ្ញវត្ថុ ។ នៅក្នុងពេលដែលគណនីរតនាគារមេត្រូវបានរក្សាទុកនៅក្នុងធនាគារកណ្តាលនោះ គណនីធនាគារដ៏ទៃទៀតរបស់រដ្ឋាភិបាល (ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់រតនាគារ) អាចមានយ៉ាងច្រើននៅក្នុងធនាគារពិណិជ្ជកម្ម ។ ក្រសួងហរិញ្ញវត្ថុខ្វះសិទ្ធិអំណាចបិទគណនីដែលស្ថិតនៅក្រៅអំណាររបស់ខ្លួន, ឧទាហរណ៍៖ គណនីរបស់ប្រធានាធិតី, ក្រសួងការពារជាតិ ។ល។ ក្រៅពីពហុគណនីដែលត្រូវបានបង្កើតឡើងដោយស្ថាប័នរបស់រដ្ឋាភិបាលនោះ, ម្ចាស់ជំនួយ និងឥណទានយកពីខាងក្រៅ ជារឿយៗទាមទារបើកគណនីពិសេស (ក៏ដូចជា នីតិវិធីស្ទូគ្រស្នាញរបស់ម្ចាស់ជំនួយជាក់លាក់) សម្រាប់ការទូទាត់ចំណាយ សម្រាប់គម្រោងអភិវឌ្ឍន៍ដែលត្រូវបានផ្តល់ហិរញ្ញប្បទានដោយម្ចាស់ជំនួយ ។ ការអនុត្តន៍បែបនេះដោយម្ចាស់ជំនួយ ឬឥណទានយក រារាំងនូវភាពពេញលេញនៃគណនីទោលរតនាគារ ។

- **សមតុល្យប្រចាំថ្ងៃនៅក្នុងគណនីរដ្ឋាភិបាលទាំងអស់មិនត្រូវបានគេដឹង** ។ ប្រសិនបើក្រសួងហិរញ្ញវត្ថុ មិនដឹងអំពីសមតុល្យចុងថ្ងៃនៅក្នុងគណនីរដ្ឋាភិបាលទាំងអស់ទេ ឬមិនអាចមិនយកមកប្រើប្រាស់សម្រាប់គោលបំណងគ្រប់គ្រងសាច់ប្រាក់បានទេនោះ, ការគ្រប់គ្រងសាច់ប្រាក់ប្រកបដោយប្រសិទ្ធិភាព និងការចំណាយតិចនោះ មិនអាចធ្វើទៅបានឡើយ ។ ដោយហេតុថា

សាច់ប្រាក់របស់រដ្ឋាភិបាលនៅក្នុងប្រព័ន្ធធនាគារ តាមធម្មតាមិនមានការប្រាក់ ឬក៏មានការប្រាក់ទាបនោះ វានាំអោយមាននូវការខាត់បង់ឱកាសយ៉ាងច្រើន[16] ។

- **កម្ចីមិនចាំបាច់កើតមានឡើង** ។ ជំនួយអោយការប្រើប្រាស់នូវសមតុល្យដែលនៅទំនេរនោះ រដ្ឋាភិបាលចេញនូវប័ណ្ណរតនាគារ ឬទំរង់ដ៏ទៃទៀតនៃបំណុល ដើម្បីធ្វើហិរញ្ញប្បទានដល់ការចាយសាច់ប្រាក់របស់ខ្លួន ។ ធនាគារពាណិជ្ជកម្មបានទទួលអត្ថប្រយោជន៍អំពីការប្រព្រឹត្តបែបនេះ ។ ទីមួយ, ធនាគារទាំងនោះ ប្រើប្រាស់នូវបញ្ញើប្រាក់រដ្ឋាភិបាលដែលនៅទំនេរ ដើម្បីទិញប័ណ្ណរតនាគារ ។ ទីពី, នៅក្នុងពេលដែលគេមិនអោយការប្រាក់សម្រាប់បញ្ញើប្រាក់របស់រដ្ឋាភិបាលនោះ គេទទួលបាននូវការប្រាក់ ពីរដ្ឋាភិបាលទៅលើប័ណ្ណរតនាគារ ដែលគេបានទិញ ។

- **ការព្យាករណ៍អំពីលំហូរសាច់ប្រាក់មិនត្រូវបានរៀបចំ** ។ ប្រទេសកំពុងអភិវឌ្ឍន៍ អាចមិនធ្វើការរៀបចំ នូវផែនការសាច់ប្រាក់រំកិលរយៈពេលខ្លីរបស់ខ្លួន ។ នេះអាចឆ្លុះបញ្ចាំងអំពីការលំបាកផ្នែកស្ថាប័ន ឬការលំបាកផ្នែកបច្ចេកទេស ដែលរួមបញ្ចូលនូវកង្វះខាតអង្គភាពគ្រប់គ្រងសាច់ប្រាក់ ដែលមានប្រសិទ្ធភាព ដែលមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីទទួលបាននូវទិន្នន័យដែលពាក់ព័ន្ធទាំងអស់ ដែលគេត្រូវការចាំបាច់ សម្រាប់បង្កើតឡើងនូវផែនការសាច់ប្រាក់ ។

- **“ការគ្រប់គ្រងសាច់ប្រាក់” មានន័យជាសំខាន់ថាជាការត្រួតពិនិត្យការចំណាយ** ។ ការគ្រប់គ្រងសាច់ប្រាក់នាសម័យទំនើប មិនខ្វល់ខ្វាយអំពីការត្រួតពិនិត្យទៅលើការអនុម័តិការចំណាយទេ ដើម្បីអោយពេលវេលានៃការចាយសាច់ប្រាក់ស៊ីគ្នាជាមួយនឹងពេលវេលានៃការទទួលសាច់ប្រាក់ ។ នៅក្នុងប្រទេសជាច្រើន ការអនុម័តិ និងការត្រួតពិនិត្យការចំណាយក្នុងឆ្នាំ ជារឿយៗត្រូវបានផ្ទេរសិទ្ធិទៅអោយក្រសួងចំណាយ ដែលទទួលខុសត្រូវរាយការណ៍ជូនអ្នកគ្រប់គ្រងសាច់ប្រាក់អំពីផែនការ

---

[16] មូលនិធិភាគច្រើនបំផុត ត្រូវបានរក្សាទុកទៅតាមបញ្ជា ដែលតាមធម្មតាផ្តល់ចំណូលទាប ឬគ្មានចំណូលតែម្តង ។ ប្រសិនបើមូលនិធិ ត្រូវបានរក្សាទុកនៅក្នុងគណនីទោលរតនាគារនោះ អ្នកគ្រប់គ្រងសាច់ប្រាក់អាចធ្វើការសម្រេចថាតើយ៉ាងហោចណាស់ចំណែកណាមួយនៃសមតុល្យ ត្រូវដាក់ជាបញ្ញើប្រាក់ដែលមានការកំណត់ពេលវេលាជាក់លាក់ ដែលនឹងបង្កើននូវចំណូល ។

សាច់ប្រាក់របស់គេ ចាពិសេសស ពេលវេលាជាក់លាក់នៃទូទាត់ចំណាយដែលមានទំហំធំៗ ។ ប្រទេសជឿនលឿន មិនយកការត្រួតពិនិត្យជាចំណាយមកធ្វើជាឧបករណ៍គ្រប់គ្រងសាច់ប្រាក់នោះទេ ពីព្រោះថា ការត្រួតពិនិត្យបែបនេះ អាចបង្កនូវបញ្ហាសម្រាប់ក្រសួងចំណាយ, បង្កើតចំណាយបន្ថែមសម្រាប់លទ្ធកម្ម និងដាក់បន្ទុកទៅលើអ្នកផ្គត់ផ្គង់ក្នុងវិស័យឯកជន ។ ផ្ទុយមកវិញ នៅក្នុងបណ្តាប្រទេសចំណូលទាបជាច្រើន "ការគ្រប់គ្រងសាច់ប្រាក់" មិនខុសពីការដាក់កំហិតសាច់ប្រាក់ទេ [17] ។ ឧទាហរណ៍៖ នៅក្នុងបណ្តាប្រទេសអាហ្វ្រិកមួយនចំនួនដែលនិយាភាសាអង់គ្លេស ប្រព័ន្ធ "ថវិកាសាច់ប្រាក់" (cash budgeting) ផ្តល់សិទ្ធអំណាចអោយអនុវត្តចំណាយ នៅក្នុងពេលដែលគេមានសាច់ប្រាក់គ្រាន់តែប៉ុណ្ណោះ ។ នៅក្នុងបណ្តាប្រទេសដែលនិយាយភាសាបារាំង "ការគ្រប់គ្រងសាច់ប្រាក់" ជារឿយៗត្រូវបានចាត់ទុកថាជាការដាក់កំហិតនូវការធានាចំណាយអោយស្ថិតនៅក្រោមកំរិតចំណាយដែលត្រូវបានអនុម័តនៅក្នុងច្បាប់ថវិកាប្រចាំឆ្នាំ ដែលមានសង្គតិភាពជាមួយនឹងសាច់ប្រាក់ដែលត្រូវបានគេរំពឹងទុកថានឹងងមាន ។ នៅក្នុងតំបន់ទាំងពីរនេះ ការកាត់បន្ថយនូវសិទ្ធអំណាចចំណាយ ពាក់ព័ន្ធជាមួយនឹងការចំណាយ "ដែលគ្មានអាទិភាព" ។ ប៉ុន្តែ លក្ខណៈវិនិច្ឆ័យសម្រាប់ការកាត់បន្ថយនេះ មិនមែនជានិច្ចកាលច្បាស់លាស់នោះទេ, ជួនកាលច្បាប់របស់ក្រសួងហិរញ្ញវត្ថុត្រូវបានគេរំលង [18] ។ ទោះបីជាម្តងម្កាល ក្រសួងហិរញ្ញវត្ថុចាំបាច់ត្រូវពន្យារ ឬលុបចោលនូវសិទ្ធអំណាចចាយថវិកាក៏ដោយ - ជា

---

[17] នៅក្នុងអតីតប្រទេសសូវៀតមួយចំនួននាទសវត្សរ៍ឆ្នាំ ១៩៩០, "ការឃុំគ្រងដោយឡែក"នូវការចំណាយ (expenditure "sequestering") កើតមានឡើងជាទូទៅ ។ នេះជាផលវិបាកដោយផ្ទាល់នៃសភាដែលអនុម័តថវិកា ដែលមានចំណូល និងចំណាយ ខ្ពស់យ៉ាងខ្លាំងជាងថវិកាសមមូល "ពិតប្រាកដ" ដែលត្រូវបានអនុវត្តដោយស្ថាប័ននីតិប្រតិបត្តិ (parallel "real" budget implemented by the executive) ។

[18] នៅក្នុងបណ្តាប្រទេសអាហ្វ្រិកជាច្រើនដែលនិយាយភាសាបារាំង, ការប្រើប្រាស់បុរេប្រទានរតនាគារសម្រាប់ការចំណាយ"បន្ទាន់" ដែលមិនត្រូវបានគ្រោងទុក ត្រូវបានរំលោភបំពាន ។ បុរេប្រទានបន្តបន្ទាប់គ្នា ត្រូវបានធ្វើឡើងសម្រាប់ការចំណាយដែលមិនត្រូវបានធ្វើថវិកា ហើយបុរេប្រទានមិនត្រូវបានធ្វើនិយ័តិកម្មអោយទៅតាមបទបញ្ញត្តិរតនាគារទេ ។ ការធ្វើរបៀបនេះ នាំអោយអស់សាច់សាច់ប្រាក់សម្រាប់ការចំណាយទៀងទាត់ដែលមាននៅក្នុងថវិកា ដែលត្រូវបានអនុវត្តទៅតាមនីតិវិធីជាបទដ្ឋាន, ដូចជា ការទូទាត់ប្រាក់ដែលត្រូវបានធ្វើឡើងបន្ទាប់ពីការពិនិពិច័យផ្ទៃក្នុង និងការផ្តល់ទំនិញ និងសេវា ។

ពិសេសនៅក្នុងពេលដែលការព្យាករណ៍ចំណូលថវិកាមានកំរិតខ្ពស់ពេក (សុទិដ្ឋិនិយមខ្លាំងពេក) - នីតិវិធីបែបនេះ មិនមែនជាធាតុដ៏ចាំបាច់របស់ការគ្រប់គ្រងសាច់ប្រាក់បែបទំនើបនោះទេ ។ ប៉ុន្តែ នៅក្នុងប្រទេសទាំងអស់ អ្នកគ្រប់គ្រង/អ្នកត្រួតពិនិត្យថវិកា ចាំបាច់ត្រូវដឹងអំពីពេលវេលា និងទំហំនៃតម្រូវការសាច់ប្រាក់ ដែលជាលទ្ធផលនៃការធានាចំណាយដែលត្រូវបានអនុម័តិ និង ធ្វើការផ្តល់នូវពត៏មានទាំងនេះ ទៅអោយអង្គភាពគ្រប់គ្រងសាច់ប្រាក់របស់ក្រសួងហិរញ្ញវត្ថុ ។

- **ការជំពាក់នូវការចំណាយបានកើតឡើង** ។ ការជំពាក់កើតឡើដោយហេតុផលផ្សេងៗគ្នា ដែលរួម មានការរៀបចំថវិកាមិនបានល្អ (ការព្យាករណ៍មិនភាពប្រកដប្រជា), ការមិនគោរពតាមនីតិវិធីអនុ វត្តន៍ថវិកា និងការគ្រប់គ្រងសាច់ប្រាក់មិនបានត្រឹមត្រូវ ។ ការមិនបានទូទាត់ប្រាក់ដោយរដ្ឋាភិបាល ទៅអោយអ្នកផ្គត់ផ្គង់នោះ គឺជាទម្រង់មួយនៃកម្ចីរដ្ឋាភិបាល ដែលមានការចំណាយខ្ពស់ ។ ទីមួយ, ការជឿទុកចិត្តទៅលើរដ្ឋាភិបាលក្នុងនាមជាអ្នកចាយប្រាក់ ត្រូវបានបន្ទាបបន្ថោក ។ ទីពីរ, អ្នកផ្គត់ ផ្គង់មានប្រតិកម្ម តាមរយៈការតម្លើងថ្លៃខ្ពស់ជាងតម្លៃធម្មតា ដើម្បីទូទាត់ចំពោះការបង់ប្រាក់យឺត យ៉ាវរបស់េដ្ឋាភិបាល ដែលត្រូវបានគេរំពឹងទុក ។ ទីបី, អ្នកផ្គត់ផ្គង់អាចមិនប្រគល់គ្រប់ចំនួន ឬមិន ផ្តល់នូវទំនិញ និងសេវាដែលមានគុណភាព ដោយការឃុបឃិតជាមួយមន្ត្រីរដ្ឋាភិបាល ។ ទីបួន, នៅ ក្នុងកិច្ចសន្យាខ្លះរបស់រដ្ឋាភិបាល ពិន័យសម្រាប់ការបង់ប្រាក់យឺតយ៉ាវ មានកំរិតខ្ពស់ជាងអត្រាការ ប្រាក់នៃកម្ចីពីធនាគារពាណិជ្ជកម្ម ។ នៅក្នុងពេលដែលការជំពាក់ការបង់ប្រាក់ ត្រូវបានដោះស្រាយ នៅក្នុងលំហាត់ជម្រះបញ្ជីអោយអស់ក្នុងពេលតែមួយដងនោះ ស្តុកនៃបំណុលរដ្ឋាភិបាលដែលមិន ទាន់ទូទាត់ និងការសងបំណុល កើនឡើងយ៉ាងគំហុក ដែលប្កផលវិបាកដល់ការគ្រប់គ្រងសាច់ ប្រាក់ ។

- **ប្រព័ន្ធ IT មិនទាន់ជឿនលឿន** ។ IMIS ដំណើរដោយប្រព័ន្ធកុំព្យូទ័រ ដែលផ្តល់នូវទិន្នន័យសំបូរបែប ជារឿយៗមានការខ្វះខាត នៅក្នុងប្រទេសដែលមានចំណូលទាប ។ ទោះបីជាវឌ្ឍនភាពត្រូវបាន ធ្វើឡើងនៅក្នុងការដាក់អោយអនុវត្តន៍នូវ IFMIS នៅក្នុងបណ្តាប្រទេសជាច្រើនក៏ដោយ, គុណ ភាពទិន្នន័យដែលមានសម្រាប់ការព្យាករណ៍ ជារឿយៗមិនមានលក្ខណៈពេញលេញតាមបទដ្ឋាន

ជាពិសេស ការផ្តល់ និងភាពទាន់ពេលវេលានៃទិន្នន័យដែលមានគុណភាពខ្ពស់ ដែលគេត្រូវការសម្រាប់ធ្វើការព្យាករណ៍យកជាការបាន ។

- **កង្វះសមត្ថភាពធនធានមនុស្ស** ។ នៅក្នុងបណ្តាប្រទេសដែលមានចំណុលទាបជាច្រើន ជារឿយៗ គេមិនមាននូវបុគ្គលិកដែលមានជំនាញចាំបាច់ ដោយសារប្រាក់ខែទាប, ការយល់ដឹងមិនបានពេញលេញអំពីសារៈសំខាន់នៃការធ្វើផែនការសាច់ប្រាក់ ឬកង្វះខាតការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំដើម្បីលុបបំបាត់នូវ "ការបាត់បង់" ដោយសារការគ្រប់សាច់ប្រាក់មិនបានល្អ ។

បញ្ហានីមួយៗខាងលើ គប្បីត្រូវបានដាក់នៅក្នុងផែនការកំណែទម្រង់ការគ្រប់គ្រងសាច់ប្រាក់ ។

## V. ការកំណត់ដំណាក់កាលកំណែទម្រង់ការគ្រប់គ្រងសាច់ប្រាក់

ផ្នែកនេះបង្ហាញអំពីដំណាក់កាលបួនដែលពាក់ព័ន្ធនៅក្នុងការរំកិលចេញពីការគ្រប់គ្រងសាច់ប្រាក់តាំងពីយូរយារមកហើយ ទៅកាន់ការគ្រប់គ្រងសាច់ប្រាក់សកម្មប្រចាំថ្ងៃ [19]។ ដំណាក់កាលទាំងនេះត្រូវបានបង្ហាញក្នុងគោលបំណងពន្យល់បំភ្លឺ - ដំណាក់កាលទាំងនេះមិនអាចនៅដាច់ដោយឡែកពីគ្នាបានទេ ។ នៅក្នុងបណ្តាប្រទេសដែលគ្មានការគ្រប់គ្រងសាច់ប្រាក់ដែលមានប្រសិទ្ធិភាព ឬដែលមាន "ការគ្រប់គ្រង" សាច់ប្រាក់ ត្រូវបានគ្របដណ្តប់ប្រព័ន្ធត្រួតពិនិត្យចំណាយនោះ, គេនឹងត្រូវការពេលវេលាជាច្រើនឆ្នាំ ដើម្បីរំកិលចេញពីដំណាក់ពីរដំបូង - ការបំពេញបុរេល័ក្ខខណ្ឌ និងការដាក់អោយអនុវត្តនូវការធ្វើផែនការសាច់ប្រាក់ជាមូលដ្ឋាន - ដើម្បីទៅដល់ដំណាក់កាលចុងក្រោយនៃការគ្រប់គ្រងសាច់ប្រាក់សកម្មប្រចាំថ្ងៃ ។

ល្បឿននៃការកែលំអការគ្រប់គ្រងសាច់ប្រាក់ ពឹងអាស្រ័យទៅលើ៖ (១) ចំណុចចាប់ផ្តើម ជាពិសេស កំរិតល័ក្ខខ័ណ្ឌជាមូលដ្ឋាន ដែលមានជាស្រេច សម្រាប់ការគ្រប់គ្រងសាច់ប្រាក់ដែលមានប្រសិទ្ធិភាព , (២) ឆន្ទៈរបស់អាជ្ញាធរជាតិក្នុងការធ្វើកំណែទម្រង់នូវការអនុវត្តន៍ក្នុងការគ្រប់គ្រងសាច់ប្រាក់, ក្នុង

---

[19] ផ្នែកនេះត្រូវបានកែសម្រួលចេញពីយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាច់ប្រាក់ ដែលត្រូវបានអធិប្បាយនៅក្នុង Williams (ឆ្នាំ 2004) ។

ការតតាំងជាមួយនឹងការជំទាស់ទៅនឹងការអភិបាលពេញលេញដោយរតនាគារទៅលើគណនីធនាគារទាំងអស់របស់រដ្ឋាភិបាល និងក្នុងការពង្រឹងតម្លាភាពនៃដំណើរការរបស់រដ្ឋាភិបាល នៅក្នុងថ្នាក់ប្រតិបត្តិការទូទាត់, (៣) ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការផ្ទេរដោយឆាប់រហ័យតាមរយៈប្រព័ន្ធអេឡិចត្រូនិក, (៤) កំរិតរីកចំរើននៃទីផ្សារហិរញ្ញវត្ថុ រួមទាំង"ការបំបាត់សមតុល្យ"ចុងថ្ងៃក្នុងគណនីក្នុងធនាគារ និងយន្តការទីផ្សារហិរញ្ញវត្ថុ ដែលមានសម្រាប់ការគ្រប់គ្រងសាច់ប្រាក់ប្រចាំថ្ងៃ, និង (៥) សមត្ថភាពធនធានមនុស្ស និងរចនាសម្ព័ន្ធស្ថាប័ន ។

## ដំណាក់កាលទី ១÷ ការដោះស្រាយធាតុជាមូលដ្ឋាន

ធាតុជាមូលដ្ឋានចំនួន ៦ នៃការគ្រប់គ្រងសាច់ប្រាក់ ដែលត្រូវបានបង្ហាញនៅក្នុងប្រអប់ ១ គឺជាបុរេល័ក្ខខ័ណ្ឌសម្រាប់ការបង្កើតឡើងនូវការគ្រប់គ្រងសាច់ប្រាក់ទំនើបដែលមានប្រសិទ្ធិភាព ។ ដោយហេតុថាគេត្រូវការចាំបាច់នូវពេលវេលាយូរអង្វែងដើម្បីបញ្ចប់ជំហានមួយចំនួននោះ, គេត្រូវតែមានភាពប្រាកដប្រជានៅក្នុងពេលដែលគេបង្កើតឡើងនូវផែនការដើម្បីបំពេញនូវជំហាន ដូចដែលត្រូវបានរាយនៅខាងក្រោមនេះ ។ ឧទាហរណ៍៖ ទោះបីជានៅក្នុងប្រទេសចំណូលទាបក៏ដោយ គេអាចត្រូវការនូវពេលវេលារហូតដល់ទសវត្សរ៍ ដើម្បីបង្កើតបាននូវគណនីទោលរតនាគារដែលមានដំណើរការ ។ ជំហានដែលត្រូវបានរាយដូចខាងក្រោមនេះ នឹងត្រូវបានបំពេញទៅតាមដំណាក់កាល ដែលជាផ្នែកនៃកំណែទម្រង់ការគ្រប់គ្រងសាច់ប្រាក់ ។

- **ការបង្កើតឡើងនូវអង្គភាពគ្រប់គ្រងសាច់ប្រាក់ (CMU)** ។ គេចាំបាច់ត្រូវបង្កើតឡើងនូវអង្គភាពបច្ចេកទេសគ្រប់គ្រងសាច់ប្រាក់នៅក្នុងក្រសួងហិរញ្ញវត្ថុ ។ អង្គភាពនេះតាមធម្មតានឹងត្រូវស្ថិតនៅក្នុងនាយកដ្ឋានរតនាគារ ទោះបីជានាយកដ្ឋានថវិកា នឹងត្រូវចូលរួមពាក់ព័ន្ធផងដែរក៏ដោយ (ជាពិសេស នៅក្នុងពេលដែលមានការពាក់ព័ន្ធនឹងការអនុវត្តន៍ថវិកា) ។
- **ការបង្កើតឡើងនូវស្ថាប័នធ្វើគោលនយោបាយស្តីអំពីការគ្រប់គ្រងសាច់ប្រាក់** ។ សម្រាប់ការធ្វើសេចក្តីសម្រេចផ្នែកគោលនយោបាយស្តីអំពីការគ្រប់គ្រងសាច់ប្រាក់ គណកម្មាធិការជាន់ខ្ពស់ ក៏ជាតម្រូវការចាំបាច់ផងដែរ ។ នៅក្នុងប្រព័ន្ធកំហិតសាច់ប្រាក់, គណៈកម្មាធិការនេះ នឹងបង្កើត

ឡើងនូវដែនកំណត់សាច់ប្រាក់អតិបរមា សម្រាប់បណ្តាក្រសួង/ស្ថាប័ន ។ នៅក្នុងស្ថានភាពបែប នេះ មានការប៉ុនប៉ងចង់អោយគណកម្មាធិការនេះ ក្លាយជាគណៈកម្មាធិការកំណត់អាទិភាព សាច់ប្រាក់ (cash triage committee) ដែលត្រូវធ្វើការសម្រេចថាវិក័យប័ត្រណាមួយដែល ត្រូវបង់ប្រាក់ និងតាមលំដាប់លំដោយបែបណា ។ ច្បាប់ច្បាស់លាស់ និងមានតម្លាភាពសម្រាប់ ការចេញបញ្ជាបង់ប្រាក់ គប្បីត្រូវបានបង្កើតឡើង ដើម្បីធ្វើអប្បរមាកម្មការពុករលួយ ។ នៅក្នុង ស្ថានភាពដែលស្មុគស្មាញជាងនេះ គណកម្មាធិការថ្នាក់គោលនយោបាយ នឹងត្រូវធ្វើសេចក្តី សម្រេចអំពីគោលនយោបាយស្តីអំពីកម្ចីរយៈពេលខ្លី, ការដាក់វិនិយោគអតិរេកបណ្តោះអាសន្ន, និងចំណូលពីសមតុល្យសាច់ប្រាក់ (cash balance remuneration) ដោយសហការជាមួយ នឹងធនាគារកណ្តាល ។

- **ការផ្តោតការយកចិត្តទុកដាក់ទៅលើសារៈសំខាន់ការគ្រប់គ្រងសាច់ប្រាក់ដែលមានប្រសិទ្ធិភាព** ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ការថ្លៃហិរញ្ញវត្ថុ សម្រាប់ការរក្សាទុកនូវសមតុល្យទំន រនៅក្នុងគណនីជាច្រើនរបស់រដ្ឋាភិបាល មិនត្រូវបានគេដឹងឡើយ ។ គេអាចមានការស្ទាក់ស្ទើរ ក្នុងការប្រាប់អោយដឹងអំពីទំហំនៃសាច់ប្រាក់រដ្ឋាភិបាល ដែលត្រូវបានលាក់ទុកនៅក្នុងគណនី ធនាគាររូបិយវត្ថុក្នុងប្រទេស ឬរូបិយវត្ថុបរទេស ដែលស្ថិតនៅក្រៅការត្រួតពិនិត្យរបស់រតនា គាតជាតិ ។ ការរកអោយឃើញ និងការផ្សព្វផ្សាយអំពីការខាតបង់ទៅលើការគ្រប់គ្រងសាច់ ប្រាក់ដែលគ្មានប្រសិទ្ធភាព លើកកំពស់នូវការយល់ដឹងអំពីការប្រព្រឹត្តល្អក្នុងការគ្រប់គ្រងសាច់ ប្រាក់ ។ ការខាតបង់ឱកាស (ការប្រាក់ដែលបាត់) ដោយសារការរក្សាទុកសមតុល្យសាច់ប្រាក់រ ដ្ឋាភិបាលអោយនៅទំនេរ ជាសាច់ប្រាក់ ឬនៅក្នុងគណនីធនាគារជាច្រើនរបស់ដ្ឋាភិបាល - រួម ទាំងការពន្យារ (float) នៅក្នុងគណនីចំណូល និគណនីងចំណាយ - គប្បីត្រូវបានគណនា ។ ការ ខាងបង់ដែលមិនជារូបរាងច្បាស់លាស់ ដូចជា ការបាត់បង់កិត្តិយសរបស់រដ្ឋាភិបាលដោយសារ ការមិនបានបង់ប្រាទាន់ពេលវេលា (គំនរនៃការជំពាក់) គប្បីត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។

- **ការធានាអោយមាននូវការព្យាករណ៍ថវិកាប្រចាំឆ្នាំដែលមានភាពប្រាកដប្រជា** ។ ទោះបីជាការ ព្យាករណ៍ចំណូលខ្ពស់ ឬការប៉ាន់ប្រមាណទាបអំពីចំណាយថវិកា មិនមែនជាបញ្ហារបស់អ្នក

គ្រប់គ្រងសាច់ប្រាក់ ដោយផ្ទាល់ក្តី, ការព្យាករណ៍ថវិកាប្រចាំឆ្នាំដែលមិនមានភាពប្រាកដប្រជា បង្កើតបញ្ហាដល់ការគ្រប់គ្រងសាច់ប្រាក់ ជាពិសេសនៅក្នុងប្រទេសដែលគ្មានជម្រើសក្នុងការខ្ចីបុល ។ នៅក្នុងពេលដែលការព្យាករណ៍ថវិកាប្រចាំឆ្នាំ និងផែនការសាច់ប្រាក់រយៈពេលខ្លី មិនត្រូវបាន ភ្ជាប់ជាមួយគ្នាអោយបានល្អនោះ ការព្យាករណ៍ចំណូលក្នុងស្រុកប្រចាំឆ្នាំគប្បីត្រូវបានធ្វើឡើង ដោយប្រុងប្រយ័ត្ន, ពេលវេលាលំហូរចូលនៃចំណូលពីជំនួយ (រួមទាំងជំនួយឥតសំណង) គប្បី ត្រូវបានគេដឹងជាក់លាក់ ហើយការគណនាតម្លៃនៃការចំណាយចរន្ត និងមូលធននៅក្នុងការ ព្យាករណ៍ថវិកាប្រចាំឆ្នាំ គប្បីត្រូវបានធ្វើឡើងអោយបានត្រូវបំផុតតាមដែលអាចធ្វើទៅបាន ។

- **ការបង្កើតឡើងនូវគណនីទោលរតនាគារដែលមានដំណើរការ** ។ គេអាចត្រូវការនូវពេលវេលាយូរ អង្វែងក្នុងការអនុវត្តន៍នូវការប្រមូលផ្តុំរាល់ចំណូលទាំងអស់របស់រដ្ឋាភិបាលទៅក្នុងគណនី ប្រតិបត្តិតែមួយក្នុងធនាគារកណ្តាល និងការទូទាត់ប្រាក់នៅក្នុងគណនីតែមួយនេះ ។ ជំហាន ដំបូង, ការជំរឿនគណនីធនាគារទាំងអស់របស់រដ្ឋាភិបាលនឹងផ្តល់នូវអត្ថប្រយោជន៍ ដែលនាំទៅ រកការបិទនូវគណនីដែលមិនត្រឹមត្រូវ ។ ការងារបន្ទាប់មកគឺការដាក់គណនីសំខាន់ទាំងអស់ របស់រដ្ឋាភិបាលអោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រតនាគារ និងការចាប់ផ្តើមអនុវត្តន៍នូវ សមតុល្យសូន្យចុងថ្ងៃសម្រាប់គណនីដែលនៅបើកទាំងនោះ ។ ការរក្សាទុកនូវបរិមាណតិចតួច នៅក្នុងគណនីដែលស្ថិតនៅក្រៅគណនីទោលរតនាគារ សម្រាប់បំរើតម្រូវការសាច់ប្រាក់តិចតួច របស់ក្រសួងចំណាយ អាចមានលក្ខណៈសមស្របជាវិធានការបណ្តោះអាសន្ន និងអាចកាត់ បន្ថយនូវការជំទាស់ទៅនឹងការផ្លាស់ប្តូរទៅរកគណនីទោលពេញលេញ ។ ដូចគ្នានេះដែរ, នៅក្នុង តំបន់ដាច់ស្រយាលនៃប្រទេស ដែលមានចំណូលទាបមួយចំនួន ដែលគ្មានធនាគារពាណិជ្ជកម្ម នោះ សាច់ប្រាក់ជាក់ស្តែងអាចត្រូវបានរក្សានៅក្នុងទូដែក និងត្រូវបានប្រើប្រាស់សម្រាប់ការ ទូទាត់ចំណាយសាច់ប្រាក់ ។
- **ការចៀសវាងនូវការប្រើប្រាស់សាច់ប្រាក់ជាក់ស្តែង** ។ នៅក្នុងពេលដែលប្រព័ន្ធធនាគារមានការ រីកចំរើននោះ ការប្រើប្រាស់សាច់ប្រាក់គប្បីត្រូវបានបំបាត់បន្តិចម្តងៗ ទាំងដោយរដ្ឋាភិបាល និង

អ្នកបង់ពន្ធ ។ នៅក្នុងពេលដែលសាច់ប្រាក់ត្រូវបានផ្ទេរចូលទៅក្នុងទូដែក មានហានិភ័យដែលថា មូលនិធិនឹងត្រូវយកទៅប្រើប្រាស់សម្រាប់គោលដៅផ្សេងទៀត ។

- **ការដាក់កំហិតបុរេប្រទានសាច់ប្រាក់** ។ នៅក្នុងប្រទេសចំណូលទាបមួយចំនួន ការបញ្ចេញបុរេប្រទានសាច់ប្រាក់ទៅអោយក្រសួង/ស្ថាប័ន អាចនាំអោយមានការខ្វះខាតសាច់ប្រាក់សម្រាប់ចំណាយ មួយចំនួនដែលត្រូវបានធ្វើថវិកា ។ ដើម្បីចៀសវាងនូវបញ្ហាបែបបនេះ បុរេប្រទានដោយរតនាគារ គប្បីត្រូវបានដាក់កំហិតទៅតាមទំហំ និងប្រភេទនៃចំណាយ ។ ម្យ៉ាងវិញទៀត ក្រសួង/ស្ថាប័ន គប្បីត្រូវបានតម្រូវអោយមានការទទួលខុសត្រូវ តាមរយៈការទាមទារអោយពួកគេធ្វើយុត្តិកម្មអំពីការប្រើប្រាស់នូវបុរេប្រទានរតនាគារ មុនពេលទទួលបាននូវបុរេប្រទានថ្មី ។

- **ការលើកកំពស់គណនេយ្យកិច្ចរបស់រដ្ឋាភិបាល** ។ ដោយសារគ្មានទិន្នន័យទាន់ពេលវេលា, ពេញលេញ និងមានគុណភាពខ្ពស់ អំពីលំហូរចូល និងលំហូរចេញហិរញ្ញវត្ថុ គេជួបប្រទះនូវការលំបាកក្នុងការរៀបចំនូវការព្យាករណ៍ និងផែនការសាច់ប្រាក់រយៈពេលខ្លីដែលមានភាពរឹងមាំ ។ ការដោះស្រាយនូវភាពកំសោយសំខាន់ៗដែលមាននៅក្នុងប្រព័ន្ធគណនេយ្យរដ្ឋាភិបាល ផ្តល់នូវមូលដ្ឋានរឹងមាំ សម្រាប់ជំហានដំបូង ឆ្ពោះទៅរកការរៀបចំនូវការព្យាករណ៍សាច់ប្រាក់រយៈពេលខ្លី ប្រកបដោយភាពត្រឹមត្រូវ ។ ការងារនេះរួមបញ្ចូលនូវការកែលំអគុណភាពទិន្នន័យគណនេយ្យ ជាពិសេស តាមរយៈការធានាថា កណត់ត្រាគណនេយ្យ និងកំណត់ត្រាធនាគារ ត្រូវបូកសរុបផ្ទៀងផ្ទាត់ពេញលេញ ដោយទៀងទាត់ ។

- **ការកែតម្រូវក្របខ័ណ្ឌច្បាប់** ។ ដើម្បីពង្រឹងនូវសិទ្ធអំណាចរបស់ក្រសួងហិរញ្ញវត្ថុនៅក្នុងការធ្វើសនិទានកម្មរចនាសម្ព័ន្ធធនាគារ និងក្នុងការបង្កើតឡើងនូវគណនីទោលរតនាគារនោះ, វិសោធនកម្មនៅក្នុងនៅក្នុងច្បាប់ និងបទបញ្ញត្តិ អាចជាប្រកាចាំបាច់ដែលគប្បីត្រូវបានធ្វើឡើង ។ ប្រសិនបើការអនុវត្តន៍នូវច្បាប់ និងបទបញ្ញត្តិដែលមានស្រាប់ មានភាពមិនច្បាស់លាស់នោះ អ្នកធ្វើសេចក្តីសម្រេច គប្បីអនុវត្តន៍នូវវិធានការ ដើម្បីពង្រឹងនូវការអនុវត្តន៍ ។

## ដំណាក់កាលទី ២៖ ការរៀបចំផែនការសាច់ប្រាក់ និងការកសាងជំនាញគ្រប់គ្រងសាច់ប្រាក់

- **ការរៀបចំនូវការព្យាករណ៍រយៈពេលខ្លីអំពីលំហូរសាច់ប្រាក់** ។ អង្គភាពគ្រប់គ្រងសាច់ប្រាក់ នឹងត្រូវទទួលខុសត្រូវទៅលើការរៀបចំនូវការព្យាករណ៍រយៈពេលខ្លីអំពីលំហូរចូល និងលំហូរចេញនៃសាច់ប្រាក់ (ដំបូងនៅលើ spreadsheets), ការវិភាគទៅលើលទ្ធផលនៃការព្យាករណ៍កន្លងទៅថ្មីៗនេះ, ការធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យ, និងការកែតម្រូវការព្យាករណ៍រយៈពេលខ្លី ។ ការយកចិត្តទុកដាក់ គប្បីត្រូវបានធ្វើឡើងដើម្បីធានាថា ពេលវេលា និងបរិមាណនៃលំហូរចូល ឬលំហូរចេញធំៗ មានភាពត្រឹមត្រូវ តាមដែលអាចធ្វើទៅបាន ។

- **ការបង្កើតឡើងនូវរចនាសម្ព័ន្ធចែករំលែកពត៌មាន** ។ បណ្តាញនៅក្នុងថ្នាក់បច្ចេកទេស គប្បីត្រូវបានបង្កើតឡើង ដោយមានតំណាងមកពីស្ថាប័នប្រមូលចំណូល, នាយកដ្ឋានរបស់ក្រសួងហិរញ្ញវត្ថុ (ជាពិសេស នាយកដ្ឋានថវិកា, នាយកដ្ឋានបំណុល និងនាយកដ្ឋានរតនាគារ), ក្រសួង និងស្ថាប័នចំណាយធំៗ និងធនាគារកណ្តាល ដើម្បីផ្តល់នូវការចូលរួមចំណែកដល់ការព្យាករណ៍អំពីលំហូរសាច់ប្រាក់រយៈពេលខ្លី ។

- **ការធានាអោយមាននូវការផ្លាស់ប្តូរពត៌មានសម្រាប់ការព្យាករណ៍សាច់ប្រាក់** ។ ដើម្បីរៀបចំនូវការព្យាករណ៍រយៈពេលខ្លីអំពីលំហូរសាច់ប្រាក់នោះ, អ្នកគ្រប់គ្រងសាច់ប្រាក់នៅក្នុងក្រសួងហិរញ្ញវត្ថុ ចាំបាច់ត្រូវទទួលបាននូវពត៌មានស្តីអំពីលំហូរចូល និងលំហូរចេញក្នុងអតីតកាល និងពត៌មានស្តីអំពីលំហូរចូល និងលំហូរចេញដែលត្រូវបានព្យាករណ៍ ។ អង្គភាពគ្រប់គ្រងសាច់ប្រាក់ គប្បីធ្វើការបែងចែកនូវលំហូរណាដែលកើតឡើងទៀងទាត់ (ឧ. នៅក្នុងថ្ងៃតែមួយនៃងខែជាក់លាក់) និងដែលជានិច្ចកាលងាយនឹងព្យាករណ៍ (ដូចជា ការប្រើប្រាស់អគ្គីសនី, ហ្គាស, ទឹកនៅក្នុងក្រសួង/ស្ថាប័នរដ្ឋាភិបាល) អោយដាច់ស្រឡះចេញពីលំហូរណាដែលមិនងាយនឹងព្យាករណ៍ ដូចជា ការទូទាត់ចំណាយសម្រាប់គម្រោងធំៗជាក់លាក់ ឬការចំណាយសម្រាប់សំណងទូទាត់ស្របច្បាប់ពីរដ្ឋ ។ នៅក្នុងពេល មានលំហូរចូលធំៗ (ដូចជា ចំណូលអំពីឯកជនភា

រូបនីយកម្មធំៗ[20]) នោះ, អ្នកគ្រប់គ្រងសាច់ប្រាក់ គប្បីត្រូវបានពិគ្រោះយោបល់ ដើម្បីធ្វើការជ្រើសរើសថ្ងៃផ្ទេរមូលនិធិចូលទៅកាន់គណនីទោលរតនាគារ នៅក្នុងពេលដែលមានលំហូរចេញប្រសើរជាងពេលដែលមានលំហូរចូល ។

- **ការរៀបចំផែនការសាច់ប្រាក់** ។ ផែនការសាច់ប្រាក់ប្រចាំខែ, ប្រចាំពីរខែម្តង, ឬប្រចាំសប្តាហ៍ គប្បីត្រូវបានរៀបចំ មុនគេ ។ គម្លាតពេលវេលារវាងផែនការនីមួយៗ គប្បីត្រូវបានពង្រួញអោយកាន់តែខ្លី បន្តិចម្តងៗ ដោយមានទិសដៅចុងក្រោយបង្អស់គឺការរៀបចំផែនការសាច់ប្រាក់ប្រចាំថ្ងៃ (សូមមើលខាងក្រោម) ។

- **ការកសាងជំនាញព្យាករណ៍សាច់ប្រាក់** ។ ការរៀបចំផែនការសាច់ប្រាក់ គឺជាលំហាត់បច្ចេកទេស ដែលទាមទារនូវបុគ្គលិកដែលមានការបណ្តុះបណ្តាល ដើម្បីធ្វើការព្យាករណ៍, តាមដាន, វិភាគ និងធ្វើបច្ចុប្បន្នភាពការព្យាករណ៍ ។ អង្គភាពគ្រប់គ្រងសាច់ប្រាក់ គប្បីត្រូវបានបំពាក់ទៅដោយបុគ្គលិក ដែលមានជំនាញសមស្រប ។

## ដំណាក់កាលទី ៣÷ ការឈានហួសពីបុរេល័ក្ខខ័ណ្ឌ និងការធ្វើផែនការសាច់ប្រាក់ជាមូលដ្ឋាន

- **ពង្រួញនូវរយៈពេលនៃការយឺតយ៉ាវក្នុងការផ្ទេរចំណូល** ។ ប្រសិនបើមានការយឺតយ៉ាវនៅក្នុងការផ្ទេរពន្ធ, ចំណូលមិនមែនពន្ធ, ជំនួយ និងចំណូលពីកម្ចី ឬមូលធន ចូលទៅក្នុងគណនីទោលរតនាគារ, វិធានការគប្បីត្រូវបានធ្វើឡើងដើម្បីពង្រួញរយៈពេលនៃការយឺតយ៉ាវ និងជាបណ្តើរៗ

[20] បរិមាណទឹកប្រាក់ដែលបានមកពីការលក់ទ្រព្យសម្បត្តិរដ្ឋ, ប្របើមានការប្រកាសលក់, អាចមិនច្បាស់លាស់ ប៉ុន្តែបរិមាណប្រហាក់ប្រហែល និងពេលវេលា ត្រូវបានគេដឹង ។

លុបបំបាត់ទាំងស្រុង ។ កិច្ចសហការជិតស្និទ្ធ រវាងស្ថាប័នប្រមូលចំណូល និងរតនាគារ គឺជាតម្រូវការចាំបាច់ [21]។

- **ការដោះស្រាយបញ្ហារដូវកាល និង "ភាពមិនទៀងទាត់" នៅក្នុងលំហូរសាច់ប្រាក់** ។ ការគ្រប់គ្រងសាច់ប្រាក់ ត្រូវបានសម្រួលនៅក្នុងពេលដែលចំណូល និងចំណាយមានភាពថេរ, ទោះបីជាមានរដូវកាលជាប់មកជាមួយនៅក្នុងចំណោមចំណូល និងចំណាយមួយចំនួនក៏ដោយ, ឧទាហរណ៍ៈ សៀវភៅអាន សម្រាប់សាលារៀន ត្រូវបានបញ្ជាទិញ និងបង់ថ្លៃម្តងក្នុងមួយឆ្នាំ ។ ប៉ុន្តែ នៅក្នុងករណីខ្លះ គេអាចមានលទ្ធភាពដាក់កំហិតរដូវកាល ។ ឧទាហរណ៍, នៅក្នុងផ្នែកចំណូល អ្នកបង់ពន្ធអាចត្រូវបានស្នើអោយបង់ពន្ធញឹកញាប់ជាងធម្មតា ដូចជា ការបង់ពន្ធប្រចាំខែជំនួសអោយការបង់ពន្ធប្រចាំត្រីមាស ។ ដោយផ្អែកទៅតាមទស្សនៈនៃការគ្រប់គ្រងសាច់ប្រាក់ ការពិនិត្យឡើងវិញទៅលើបទបញ្ញត្តិពន្ធ អាចជាលំហាត់ធ្វើក្នុងពេលតែមួយដង ដែលផ្តល់នូវអត្ថប្រយោជន៍ ។ សម្រាប់ប្រទេសដែលពឹងផ្អែកទៅលើជំនួយ ការបញ្ចេញសាច់ដែលកាន់តែមានភាពទៀងទាត់ និងដែលកាន់តែអាចព្យាករណ៍បាន ដោយម្ចាស់ជំនួយ នឹងផ្តល់នូវអត្ថប្រយោជន៍ដ៏ច្រើនបំផុតដល់អ្នកធ្វើផែនការសាច់ប្រាក់ ។ នៅក្នុងផ្នែកចំណាយ, ប្រទេសចំណូលទាប និង

[21] នៅក្នុងសហរដ្ឋអាមេរិក, គណនីរតនាគារសម្រាប់ពន្ធ និងកម្ចីពិសេស (TT&L) ត្រូវបានប្រើប្រាស់ដើម្បីរក្សានូវមូលនិធិរតនាគារដែលត្រូវបានវិនិយោគនៅក្នុងធនាគារពាណិជ្ជកម្ម រហូតដល់ពេលដែលមូលនិធិនេះត្រូវបានគេត្រូវការ ។ ការធ្វើរបៀបនេះ អាចបង្ហាញថា ចំណូលពន្ធនឹងមិនបានចាកចេញពីប្រព័ន្ធធនាគារពាណិជ្ជកម្មទេ ។ ប៉ុន្តែ ប្រាក់បញ្ញើនៅក្នុងគណនី TT&L ត្រូវបានធានាពេញលេញ, បង់ការប្រាក់ទាមទីផ្សារ, និងត្រូវបានដកយកមកវិញនៅក្នុងពេលដែលគេត្រូវការវា ។ ចំណាត់ការបែបនេះ មានភាពស្រដៀងគ្នាទៅនឹងការអោយខ្ចីឡើងវិញនូវអតិរេកសាច់ប្រាក់រដ្ឋាភិបាលសហព័ន្ធ ទោះបីជាវាមិនត្រូវបានផ្ទេរដោយជាក់ស្តែងតាមរយៈគណនីទោលរតនាគារ ដែលត្រូវបានរក្សានៅក្នុងធនាគារបំរុងសហព័ន្ធ នាទីក្រុងញូយ៉ក ក៏ដោយ ។

មធ្យម អាចតម្រូវអោយធ្វើការពិនិត្យឡើងវិញទៅលើនីតិវិធីអនុវត្តន៍ថវិកា និងច្បាប់ស្តីអំពីការរំកិលទៅក្នុងឆ្នាំខាងមុខនូវមូលនិធិដែលនៅសល់
(carry-over rules) ដើម្បីចៀសវាងនូវការព្យាយាមចំណាយនៅក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនៃឆ្នាំហិរញ្ញវត្ថុ, មានន័យថា ដើម្បីលុបបំបាត់នូវផ្នត់គំនិតដែលថា "គេត្រូវតែចាយវាពុំនោះសោតទេ នឹងបាត់បង់វា" ។

- **ការវាយតម្លៃអំពីផលប៉ះពាល់របស់ការធានាចំណាយដែលកំពុងត្រូវបានធ្វើផែនការ ទៅលើការព្យាករណ៍សាច់ប្រាក់** ។ សេចក្តីសម្រេចអំពីការអនុវត្តន៍នូវការចំណាយថវិកា តាមធម្មតាត្រូវបានធ្វើឡើងដោយអ្នកគ្រប់គ្រង ថវិកានៅក្នុងក្រសួង និងស្ថាប័នចំណាយ ។ អ្នកគ្រប់គ្រងថវិកា ដែលមានការទទួលខុសត្រូវទៅលើការចំណាយធំៗ គប្បីត្រូវបានទាមទារផ្ញើរជូនយ៉ាងទៀងទាត់ដល់រតនាគារនូវកាលវិភាគរំពឹងទុកនៃ បញ្ចេញសាច់ប្រាក់ របស់ការធានាចំណាយដែលមិនទាន់ទូទាត់ ដើម្បីអោយរតនាគារអាចដាក់បញ្ចូលនូវកាលវិភាគទាំងនេះ នៅក្នុងពេលធ្វើបច្ចុប្បន្នភាពផែនការសាច់ប្រាក់ ។ អ្នកគ្រប់គ្រងថវិកា ត្រូវតែដឹងអំពីការយឺតយ៉ាវដែលអាចកើតមានឡើងនៅក្នុងដំណើរលទ្ធកម្មរបស់រដ្ឋាភិបាល ។ ប្រសិនបើចាំបាច់ នីតិវិធីធ្វើកិច្ចសន្យារបស់រដ្ឋាភិបាល អាចត្រូវបានពិនិត្យឡើងវិញ ដើម្បីកាត់បន្ថយនូវការពន្យារពេលក្នុងលទ្ធកម្ម ដែលនឹងជួយបង្កើនូវភាពត្រឹមត្រូវនៃការព្យាករណ៍អំពីតម្រូវការសាច់ប្រាក់ដែលមាននៅក្នុងកិច្ចសន្យាលទ្ធកម្ម ដែលកំពុងត្រូវបានធ្វើផែនការ ។

- **ដំណើការអនុម័តិចំណាយ និងការទូទាត់ចំណាយ ប្រកបដោយប្រសិទ្ធភាព** ។ នៅក្នុងដែលមានដំណើរការអនុម័តិចំណាយប្រកបដោយភាពស្មុគស្មាញនោះ, គ្រប់ការត្រួតជាន់គ្នាទាំងអស់នៃការទទួលខុសត្រូវរបស់តួអង្គជាច្រើន ដែលពាក់ព័ន្ធនៅក្នុងការចាត់ចែងដោយផ្ទាល់ គប្បីត្រូវបាលុបបំបាត់ ។ ឧទាហរណ៍, នៅក្នុងប្រទេសអាមេរិកឡាទីនមួយចំនួន ការិយាល័យសវនកម្មពីខាងក្រៅ ធ្វើការអនុម័តិគ្រប់សំណើចំណាយទាំងអស់ (និងក្នុងករណីខ្លះ ចុះហត្ថលេខាលើនៅមូលប្បទានប័ត្រទៀតផង) ។ បុរេសវនកម្មបែបនេះ ធ្វើឡើងវិញនូវការពិនិត្យពិច័យដែលត្រូវបានធ្វើ

រួចហើយ ដោយក្រសួងរបស់រដ្ឋាភិបាល ដែលអាចត្រូវការកសាងនូវសមត្ថភាពសវនកម្មផ្ទៃក្នុងរបស់ខ្លួន ។

- **ការដាក់បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រនូវដំណើរការចំណាយ** ។ កំណើននៃការពឹងផ្អែកទៅលើដំណើរការតាមប្រព័ន្ធកុំព្យូទ័រ និងការទូទាត់ចំណាយតាមប្រព័ន្ធអេឡិចត្រូនិក អាចកាត់បន្ថយនូវការយឺតយ៉ាវ រវាងការធានាចំណាយ និងចំណាយជាក់ស្តែង និងកាត់បន្ថយនូវប្រការចាំបាច់ដែលគេត្រូវប្រើប្រាស់នូវការត្រួតពិនិត្យការធានាចំណាយដែលជាធាតុនៃការគ្រប់គ្រងសាច់ប្រាក់ប្រកបដោយប្រសិទ្ធិភាព [22]។

- **ការរក្សាទុកនូវសមតុល្យសាច់ប្រាក់អប្បបរមា** ។ សមតុល្យដែលមិនមានការប្រាក់ គប្បីត្រូវបានកាត់បន្ថយអោយស្ថិតនៅក្នុងកំរិតទាបបំផុត ។ ប៉ុន្តែ សមតុល្យសាច់ប្រាក់អប្បបរមា គប្បីត្រូវបានរក្សាទុក នៅក្នុងពេលដែលការគ្រប់គ្រងសាច់ប្រាក់ "ដោយការគណនាត្រួសៗ" ត្រូវបានគេអនុវត្ត ។ ដែនកំណត់ (threshold) សម្រាប់សមតុល្យសាច់ប្រាក់ មានកំរិតខ្ពស់ជាងដែនកំណត់សាច់ប្រាក់ នៅក្នុងស្ថានភាពដែលសាច់ប្រាក់ត្រូវបានគ្រប់គ្រងសកម្មប្រចាំថ្ងៃ (សូមមើលខាងក្រោម) ។

- **ការផ្តល់ការប្រាក់ដល់សមតុល្យសាច់ប្រាក់ដែលនៅទំនេរ។** វាគឺការអនុវត្តន៍ល្អរបស់ធនាគារកណ្តាល ដែលផ្តល់ការប្រាក់ដល់សមតុល្យសាច់ប្រាក់រដ្ឋាភិបាល នៅក្នុងដែនកំណត់អប្បបរមា (IMF, ឆ្នាំ1999) ។ ការចរចារជាមួយធនាគារកណ្តាល គឺជាប្រការចាំបាច់ ដើម្បីកែតម្រូវនូវស្ថានភាព ដែលរតនាគារ មិនបានទទួលការប្រាក់ត្រឹមត្រូវ [23] ។ ជាគោលការណ៍, ការផ្តល់ការ

---

[22] សូមមើលកំណត់សម្គាល់ណែនាំ No. 4 ស្តីអំពីការត្រួតពិនិត្យការធានាចំណាយ ដែលមាននៅក្នុងវេបសាយធ៍៖

http://blog-pfm.imf.org ។

[23] ជួនកាល ការចរចារអាចមានការលំបាក ។ ធនាគារកណ្តាល មានការបារម្ភអំពីតារាងសមតុល្យ និងគណនីចំណេញ និងខាតបង់របស់ខ្លួន ។ ឧទាហរណ៍: ធនាគារកណ្តាល អាចមានកាតព្វកិច្ចរក្សាទុកនូវទ្រព្យដែល

ប្រាក់សម្រាប់បញ្ញើប្រាក់រដ្ឋាភិបាល គប្បីត្រូវបានផ្សារភ្ជាប់ជាមួយនឹងអត្រាការប្រាក់តាមទីផ្សារ ។

- **ការពង្រីកនូវការគ្របដណ្តប់របស់គណនីទោលរតនាគារ** ។ រតនាគារគប្បីទទួលបាននូវបាននូវសិទ្ធិ ចូលទៅកាន់គណនីធនាគារទាំងអស់របស់រដ្ឋាភិបាល ដើម្បីគ្រាន់តែខ្ចីតែប៉ុណ្ណោះនៅក្នុងពេលចាំបាច់ ។ រាល់សមតុល្យគណនីធនាគារមិនមែន TSA ទាំងអស់ (នៅក្រៅថវិកា) ដែលនៅទំនេរ គប្បីត្រូវបានប្រើប្រាស់គោលបំណងនៃការគ្រប់គ្រងសាច់ប្រាក់ ប្រសិនបើគ្មានការហាមឃាត់ស្របច្បាប់ ដែលរារាំងនូវការប្រើប្រាស់បែបនេះទេ ។ ប្រសិនបើចាំបាច់, ចំណាត់ការអាចត្រូវបានធ្វើឡើងដើម្បីផ្តល់កម្ចីនូវសាច់ប្រាក់ទៅអោយរតនាគារ [24]។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍, ម្ចាស់ជំនួយគប្បីអនុញ្ញាតិ អោយមានការបញ្ចេញនូវជំនួយឥតសំណង ឬកម្ចី ទៅក្នុងគណនីពិសេស ដែលត្រូវបានប្រើប្រាស់ សម្រាប់គ្រប់គ្រងសាច់ប្រាក់ នៅក្នុងប្រទេសទទួលជំនួយ[25] ។

---

មិនផ្តល់ផលចំណេញល្អ (underperforming assets) ទៅតាមសំណើរបសរដ្ឋាភិបាល ដូចជា ប័ណ្ណបំណុលពិសេស (special bond) ដែលត្រូវបានចេញ ដើម្បីកែទំរង់ប្រព័ន្ធធនាគារ ។ ធនាគារក៏អាចមានអំណះអំណាងថា “ដោយសារយើងផ្ទេរនូបការចំណេញរបស់យើងទៅអោយរដ្ឋាភិបាលនៅចុងឆ្នាំនោះ វាមិនមានបញ្ហទេ” ។ ប៉ុន្តែ ការចំណេញរបស់ធនាគារកណ្តាល មិនដែលត្រូវបានផ្ទេរទាំងស្រុងនោះទេ (សេវាទូទៅ និងពិសេស ត្រូវបានរក្សាទុក) ហើយពេលវេលានៃការផ្ទេរ មានភាពមិនទៀងទាត់ ។

24 ឧទាហរណ៍នៅក្នុងប្រទេសប្រេស៊ីល ដែលច្បាប់ផ្តល់អោយស្ថាប័នមួយចំនួននូវស្វ័យតិភាពនៅក្នុងការគ្រប់គ្រងធនធានផ្ទាល់ខ្លួនរបស់គេ ដែលជាការលើទឹកចិត្តដល់ពួកគេអោយផ្ទេរមូលនិធិចូលទៅក្នុងគណនីទោលរតនាគារ ។ បញ្ញើប្រាក់របស់គេ (នៅពេលត្រូវបានផ្ទេរ) បានទទួលនូវការប្រាក់ក្នុងអត្រាប្រហាក់ប្រហែលគ្នានឹងអត្រាដែលត្រូវបានបង់ដោយ ធនាគារកណ្តាលទៅលើបញ្ញើប្រាក់ក្នុងគណនីទោលរតនាគារ ។

25 ការធ្វើរបៀបនេះនឹងជួយលើកកំពស់នូវភាពស៊ីសង្វាក់គ្នានៃនីតិវិធី ដូចដែលត្រូវបានចែងនៅក្នុងសេចក្តីប្រកាសទីក្រុងប៉ារីសស្តីអំពីប្រសិទ្ធិភាពនៃជំនួយ, សូមមើលៈ http://www.oecd.org/searchResult/0,3400,en_2649_201185_1_1_1_1_1,00.html

- **ការសម្របសម្រួលរវាងការគ្រប់គ្រងសាច់ប្រាក់ និងការគ្រប់គ្រងបំណុល** ។ នៅក្នុងពេលដែលមុខងារគ្រប់គ្រងបំណុលរបស់រដ្ឋាភិបាលកំពុងមានដំណើរការទៅមុខ - រួមទាំងការចេញប័ណ្ណរតនាគារ តាមទីផ្សារក្នុងស្រុក និងការចេញប័ណ្ណបំណុលតាមទីផ្សារអន្តរជាតិ - ការសម្របសម្រួលជិតស្និទ្ធ គឺជាតម្រូវការចាំបាច់ដែលគប្បីត្រូវបានធ្វើឡើង រវាងអ្នកគ្រប់គ្រងសាច់ប្រាក់ និងអ្នកគ្រប់គ្រងបំណុល ដើម្បីបង្កើតឡើងនូវកម្មវិធីចេញប័ណ្ណបំណុល ដែលគិតគូរទៅដល់ស្ថានភាពសាច់ប្រាក់ (cash profile) ដើម្បីចៀសវាងនូវការចេញបំណុលដែលមិនចាំបាច់ និងដើម្បីធានាថា អន្តរកម្មរវាង លុយ និងទីផ្សារប័ណ្ណបំណុល ត្រូវបានចាត់ចែងប្រកបដោយភាពស៊ីសង្វាក់គ្នា ។

- **ការប្រើប្រាស់សេវាធនាគារ** ។ វិធីសាស្ត្រទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក កំពុងត្រូវបានដាក់អោយអនុវត្តនៅក្នុងប្រទេសជាច្រើន ។ បន្ទាប់ពីលុបបំបាត់ជាបណ្តើរៗនូវប្រតិបត្តិការជាសាច់ប្រាក់ជាក់ស្តែងនោះ, ជំហានបន្ទាប់មក គឺការលុបបំបាត់ជាបណ្តើរៗនូវការប្រាស់ប្រាស់មូលប្បទានប័ត្រ តាមរយៈការជំនួសនូវការទូទាត់តាមឯកសា រដោយការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ។ ឧទាហរណ៍, គេអាចធ្វើចាប់ផ្តើមដំណើរការនេះ ដោយតម្រូវអោយមន្ត្រីរាជការស៊ីវិជាន់ខ្ពស់បើកគណនីក្នុងធនាគារពាណិជ្ជកម្ម ដែលប្រាក់ខែរបស់គេត្រូវបានផ្ទេរដោយផ្ទាល់ចូលទៅក្នុងគណនីនោះ ។ ការកែលំអនៅក្នុងការប្រើបាស់បណ្តាញទូទាត់អេឡិចត្រូនិកផ្ទេក្នុងធនាគារ (មានន័យថា RTGS) លុបបំបាត់ការយឺតយ៉ាវក្នុងការទូទាត់ចំណាយ និងលុបបំបាត់នូវតម្រូវការរក្សាទុកនូសមតុល្យនៅក្នុងគណនីធនាគាររដ្ឋាភិបាល ដែលស្ថិតខាងក្រៅគណនីប្រតិបត្តិមេក្នុងធនាគារកណ្តាល ។

- **ការធ្វើអោយទៅជាផ្លូវការនូវទំនាក់ទំនងជាមួយធនាគារដើម្បីអោយគេផ្តល់សេវារតនាគារ** ។ ធនាគារពាណិជ្ជកម្ម គប្បីត្រូវបានផ្តល់នូវកិច្ចសន្យា - តាមរយៈការដេញថ្លៃប្រកបដោយការ

ប្រកួតប្រជែង ប្រសិនអាចធ្វើទៅបាន [26] - ដើម្បីអោយគេផ្តល់សេវាប្រតិបត្តិការទៅកាន់រតនាគារ ។ ការប្រើប្រាស់នូវធនាគារពាណិជ្ជកម្ម មានប្រសិទ្ធិភាពចំណាយ (efficient) ជាងការបង្កើតបណ្តាញសាខារតនគារ [27] , ដោយហេតុថា ការផ្តល់នូវសេវាប្រតិបត្តិការ (transactions services) គឺជាជំនាញស្នូលរបស់ធនាគារ និងការចំណាយត្រូវបានកាត់បន្ថយ (សេដ្ឋកិច្ចមាត្រដ្ឋាន) ។ ធនាគារកណ្តាល តាមធម្មតា មានសាខាតិចតួច ។ វាមិនមែនជាតួនាទីរបសធនាគារកណ្តាលទេក្នុងការផ្តល់សេវារាយធនាគារ ទៅអោយរដ្ឋាភិបាល ។

- **ការបញ្ជាក់ច្បាស់លាស់អំពីទំនាក់ទំនងរវាងរតនាគារ និងធនាគារកណ្តាល ។** ដើម្បីលើកកំពស់តម្លាភាពនៃទំនាក់ទំនងរវាងធនាគារកណ្តាល (ឯករាជ្យ) និងរតនាគារ រចនាសម្ព័ន្ធសម្រាប់ការពិគ្រោះយោបល់ រវាងអ្នកគ្រប់គ្រងសាច់ប្រាក់រដ្ឋាភិបាល និងធនាគារកណ្តាល អាចត្រូវបានគ្របដណ្តប់ដោយអនុសារណៈនៃការយោគយល់គ្នា ។ វាក៏ជាប្រការដ៏ល្អផងដែរ ដែលគេត្រូវបង្កើតឡើងនូវ "កិច្ចព្រៀងផ្តល់សេវា" ដែលអធិប្បាយលំអិតអំពីសេវាដែលនឹងត្រូវបានផ្តល់អោយដោយធនាកណ្តាល ។ បញ្ហាដែលត្រូវបានគ្របដណ្តប់នៅក្នុង"កិច្ចព្រៀងផ្តល់សេវា" អាចរួមបញ្ចូលនូវ: (១) ការផ្តល់ដំណឹងដែលភាគីទាំងពីរនឹងត្រូវផ្តល់អោយស្តីអំពីការផ្លាសប្តូរដែលជិតនឹងកើតឡើងនៅក្នុងកាលវិភាគប្រតិបត្តិ (operational timetable), ឧទាហរណ៍: ការប្រកាសលក់ ឬការប្រកាសផ្សេងៗ, (២) ពេលវេលាដែលធនាគារកណ្តាលត្រូវសម្រេចបានក្នុងការចាត់ចែងប្រតិបត្តិការរដ្ឋាភិបាល, (៣) ការចែករំលែកលំហូរពត៌មានទាំងអំពីនិន្នាការ និងសម

---

[26] នៅក្នុងករណីដែលប្រព័ន្ធធនាគារ ង ហើយការប្រកួតប្រជែងមានកំរិតតិចតួចនោះ, រតនាគារអាចបង្កើតឡើងនូវច្បាប់ សម្រាប់ជ្រើសរើសធនាគារណាដែលមានចេតនាផ្តល់សេវាធនាគាររតនាគារសម្រាប់រដ្ឋាភិបាល, ឧទាហរណ៍: រតនាគារ លើកសំណើរការប្រាក់ ដោយផ្អែកទៅលើថ្លៃប៉ាន់ប្រមាណក្នុងមួយប្រតិបត្តិការ ។

[27] នៅក្នុងប្រទេសដែលបណ្តាញនៃសាខារតនាគារ ត្រូវបានបង្កើតឡើងរួចហើយតាំងពីដំបូង (ដូចជា ប្រទេសដែលនិយាយភាសាបារាំង) នោះគេគប្បីបន្តប្រើប្រាស់នូវសេវា "ធនាគារ" ក្នុងបណ្តាញរតនាគារ ។

តុល្យក្នុងគណនី, (៤) ថ្លៃគណនី, ថ្លៃសេវាដែលត្រូវបានបង់រួចហើយ និងមូលដ្ឋានសម្រាប់គណនា, (៥) កំហិត និងល័ក្ខខ័ណ្ឌទៅលើការខ្ចីពីធនាគារកណ្តាល[28], និង (៦) ការដោះស្រាយគ្រប់បញ្ហានៅក្នុងការបន្តធុរកិច្ច ។

## ដំណាក់កាលទី ៤៖ ការដាក់អោយអនុវត្តន៍នូវការគ្រប់សាច់ប្រាក់សកម្មប្រចាំថ្ងៃ

ស្របពេលជាមួយគ្នាដែលប្រតិបត្តិការគ្រប់គ្រងសាច់ប្រាក់រដ្ឋាភិបាលមានដំណើរការទៅមុខនោះ, គេចាំបាច់ត្រូវឈានអោយហួសពីដំណាក់កាលបន្ទាន់បែប "rough-tuning" - ការប្រើប្រាស់នូវការចេញ ប័ណ្ណរតនាគាររយៈពេលខ្លី ដើម្បីបំបាត់នូវបញ្ហានូវសមតុល្យសាច់ប្រាក់ - និងធ្វើការផ្តោតការយកចិត្តទុកដាក់ទៅលើការគ្រប់គ្រងប្រចាំថ្ងៃនូវសាច់ប្រាក់ដែលមាន ។ ការកែលំអដូចខាងក្រោមនេះ អាចត្រូវបានធ្វើឡើង៖

- **ការធ្វើអោយមានភាពកាន់តែសកម្មនៅក្នុងការគ្រប់គ្រងសមតុល្យសាច់ប្រាក់ប្រចាំថ្ងៃ** ។ នៅក្នុងពេលដែលគេមានឧបករណ៍សម្រាប់ "ការសម្រិតសម្រាំង" ហើយការធ្វើបច្ចុប្បន្នភាពនៃការព្យាករណ៍រយៈពេលខ្លីត្រូវបានគេធ្វើឡើងកាន់តែញឹកញាប់នោះ, កំរិតសាច់ប្រាក់ប្រតិបត្តិ (operating target) សម្រាប់សមតុល្យប្រចាំថ្ងៃក្នុងគណនីទោលរតនាគារ គប្បីត្រូវបានបង្កើតឡើង ។ រាល់អតិរេកបណ្តោះអាសន្ន នឹងត្រូវបានវិនិយោគនៅក្នុងទីផ្សារហិរញ្ញវត្ថុ ។ សូម្បីតែប្រទេសដែលមិនមានកំរិតសាច់ប្រាក់ប្រតិបត្តិ (operation target) ប្រចាំថ្ងៃក៏ដោយ, ឧទាហរណ៍: ប្រទេសអូស្ត្រាលី, ការិយាល័យគ្រប់គ្រងសាច់ប្រាក់ មានគោលបំណងកាត់បន្ថយនូវប្រែប្រួលប្រចាំថ្ងៃនៃសមតុល្យសាច់ប្រាក់ក្នុងគណនីទោលរតនាគារ ។

---

[28] ប្រទេសមួយចំនួន (ដូចជា សមាជិកសហគមន៍អឺរ៉ុប និងសហភាពរូបិយវត្ថុអាហ្វ្រិកបស្ចឹម និងអាហ្វ្រិកកណ្តាល) ធ្វើការហាមឃាត់មិនអោយរដ្ឋាភិបាលខ្ចីប្រាក់ពីធនាគារកណ្តាល ។ ទោះបីជាប្រទេសអាមេរិកឡាទីនជាច្រើនបានធ្វើការកែប្រែច្បាប់ដើម្បីហាមឃាត់នូវការខ្ចីពីធនាគារកណ្តាលក៏ដោយ, ប្រទេសអាមេរិកឡាទីនមួយចំនួននៅបន្តអនុញ្ញាតិអោយមានការខ្ចីបែបបនេះ ។

- **ការដាក់អោយអនុវត្តនូវរចនាសម្ព័ន្ធ "សំអាត" គណនីធនាគារប្រចាំថ្ងៃ** ។ នៅក្នុងប្រទេសដែលមុខងារនៃការគ្រប់គ្រងសាច់ប្រាក់ត្រូវបានផ្ទេរសិទ្ធិនោះ, ស្ថាប័នថវិកានីមួយៗត្រូវបានផ្តល់អំណាចអោយមានគណនីប្រតិបត្តិការដាច់ដោយឡែក ដែលតាមរយៈគណនីទាំងនេះគេអាចធ្វើការទូទាត់ចំណាយ ។ ប៉ុន្តែ រាល់សមតុល្យទាំងអស់នៅក្នុងគណនីទាំងនេះ ត្រូវបានផ្ទេរអស់ ចូលទៅក្នុងគណនីទោលរតនាគារ យ៉ាងណាស់ម្តងជាប្រចាំថ្ងៃ [29] ។ ការងារនេះអាចសម្រេចទៅបាន ក្នុងករណីដែលប្រព័ន្ធធនាគារអេឡិចត្រូនិក អនុញ្ញាតិអោយមានសំអាត និងទូទាត់ប្រចាំថ្ងៃ នៅក្នុងគណនីធនាគាររដ្ឋាភិបាល ។

- **ការធានាសន្តិសុខដោយរតនាគារសម្រាប់ការវិនិយោគរយៈពេលខ្លី** ។ ការប្រើប្រាស់នូវបញ្ញើប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុដែលមានការធានា ដូចជា កិច្ចសន្យាទិញហើយលក់វិញ (reverse repos) (ដែលត្រូវបានធានាពេញលេញ), លុបបំបាត់នូវហានិភ័យ ។ តម្រូវការអោយមាននូវរបស់បញ្ចាំពេញលេញសម្រាប់ការវិនិយោគបណ្តោះអាសន្ន មានសារៈសំខាន់ខ្លាំងណាស់ នៅក្នុងប្រទេសដែលមានប្រវត្តិធនាគារងាយទន់ខ្សោយ ។ នៅក្នុងប្រទេសដែលមានប្រព័ន្ធធនាគាររឹងមាំ ការវិនិយោគនូវចំណែកតូចនៃសមតុល្យរតនាគារ ជួនកាលត្រូវបានធ្វើឡើងដោយគ្មានការ

---

[29] នៅក្នុងពេលដែល "ការសំអាត" សមតុល្យគណនីធនាគារក្នុងប្រទេសជឿនលឿនជាច្រើន ត្រូវបានធ្វើឡើងម្តងក្នុងមួយថ្ងៃនោះ, ប្រទេស Sweden ធ្វើការសំអាតគណនីធនាគារប្រហែលជា ២៤០ បីដងក្នុង ១ថ្ងៃ ។ ជាមួយនឹងការគ្រប់គ្រងសាច់ប្រាក់ប្រចាំថ្ងៃប្រកបដោយភាពសកម្មបែបនេះ ប្រទេស Sweden អាចរក្សាបាននូវសមតុល្យសូន្យចុងថ្ងៃ នៅក្នុងគណនីទោលរតនាគាររបស់ខ្លួន ដែលត្រូវបានរក្សានៅក្នុងធនាគារកណ្តាលនៃប្រទេស Sweden (សូមមើល Swedish National Debt Office, ឆ្នាំ 2006), មានន័យថា សមតុល្យសាច់ប្រាក់ដែលគោលដៅ នាចុងថ្ងៃនីមួយៗ គឺសូន្យ (សូមមើលប្រទេស និងសមតុល្យ ដែលត្រូវបានបង្ហាញនៅក្នុងសំណត់សំគាល់ចុងទំព័រលេ ១១) ។

ធានា ទោះបីជាការពិចារណាអំពីហានិភ័យឥណទាន ត្រូវបានធ្វើឡើងនៅក្នុងគ្រប់ការសម្រេចអំពីការវិនិយោគក៏ដោយ [30]។

- **ការសម្រិតសម្រាំងការព្យាករណ៍លំហូរសាច់ប្រាក់** ។ នៅក្នុងពេលដែលការយកចិត្តទុកដាក់ត្រូវបានធ្វើឡើងទៅលើការព្យាករណ៍ប្រចាំថ្ងៃអំពីលំហូរចូល និងលំហូរចេញក៏ដោយ, ភាពត្រឹមត្រូវនៃការព្យាករណ៍ តម្រូវអោយមានការកែលំអ រួមទាំងពេលពិតប្រាកដនៃប្រតិបត្តិការដែលមានតម្លៃធំៗ ។ គេចាំបាច់ត្រូវមាននូវក្រុមដែលមានសមត្ថភាពត្រឹមត្រូវ ដើម្បីធ្វើការសម្រិតសម្រាំងនូវការព្យាករណ៍ប្រកបដោយការយកចិត្តទុកដាក់ (ជាពិសេសសម្រាប់ថ្ងៃឆាប់ៗខាងមុខ), ដែលស្របទៅតាមពត៌មានថ្មីៗស្តីអំពីលំហូរជាក់ស្តែង ។ គេក៏ត្រូវការផងដែរនូវសមត្ថភាពសម្រិតសម្រាំងការព្យាករណ៍ ប្រចាំថ្ងៃ [31]។ ការព្យាករណ៍ប្រចាំថ្ងៃ គប្បីគ្របដណ្តប់រយៈពេលយ៉ាងហោចណាស់ពី ២ ទៅ ៣ខែ [32]។ ការសម្រិតសម្រាំងការព្យាករណ៍ ទាមទារអោយមាននូវការកែលំអនៅក្នុងការផ្តល់យោបល់ត្រឡប់ពីស្ថាប័នប្រមូលចំណូលសម្រាប់ការព្យាករណ៍ចំណូល និងយោបល់ត្រឡប់ពីក្រសួង និងស្ថាប័ន ស្តីអំពីតម្រូវការសាច់ប្រាក់របស់គេ និងដោយមានធនាគារកណ្តាលសម្រាប់ការពិគ្រោះយោបល់ស្តីអំពីអន្តរាគមន៍ទីផ្សារដែលត្រូវបានស្នើឡើងដោយរត

---

[30] ទោះបីជានៅក្នុងប្រទេសអភិវឌ្ឍន៍ក៏ដោយ សេចក្តីសម្រេចប្រកបដោយការធ្វេសប្រហែស អាចត្រូវបានធ្វើឡើង ។

ឧទាហរណ៍: សូមមើលករណីនៃអាជ្ញាធរក្រុងក្នុងរដ្ឋ Florida នៃសហរដ្ឋអាមេរិក ដែលត្រូវបានរាយការណ៍នៅក្នុង http://blog-pfm.imf.org/pfmblog/2008/01/cash-management.html.

[31] នៅក្នុងចក្រភពអង់គ្លេស នៅត្រឹមម៉ោង ២ ល្ងាច រដ្ឋាភិបាលបានទទួល ៦០% នៃការបង់ពន្ធនៅទូទាំងប្រទេស ដែលខ្លួនអាចប្រមូលបាននៅក្នុងថ្ងៃនោះ (សូមមើល Williams, 2003) ។ ពត៌មាននេះ ត្រូវបានប្រើប្រាស់សម្រាប់ការព្យាករណ៍ ។

[32] ប្រទេសជឿនលឿន តាមធម្មតាមានការព្យាករណ៍សម្រាប់រយៈពេលវែលជាង នៅក្នុងករណីខ្លះសម្រាប់រយៈពេលជាច្រើនខែ, ឧទាហរណ៍៖ ១២ខែ សម្រាប់ប្រទេសបារាំង, ៩ខែ សម្រាប់សហរដ្ឋអាមេរិក ។

នាគារ ។ ការលើកទឹកចិត្ត អាចត្រូវបានផ្តល់អោយ ដើម្បីលើកទឹកចិត្តដល់ស្ថាប័នចំណាយ ដើម្បីអោយពួកគេធ្វើការកែលំអនូវភាពត្រឹមត្រូវក្នុងការព្យាករណ៍អំពីតម្រូវការសាច់ប្រាក់របស់គេ (សូមមើលកំណត់សំគាល់ចុងទំព័រលេខ ១៣) ។

- **ការពង្រឹងការសម្របសម្រួល** ។ ការគ្រប់គ្រងសាច់ប្រាក់ប្រចាំថ្ងៃ ទាមទារអោយមាននូវយ៉ាងទៀងទាត់ រវាងអ្នកគ្រប់គ្រងសាច់ប្រាក់, អ្នកគ្រប់គ្រងបំណុលរដ្ឋាភិបាល និងអាជ្ញាធររូបិយវត្ថុ ។ ការសម្របសម្រួល មានសារៈសំខាន់ខ្លាំងណាស់នៅក្នុងពេលអ្នកគ្រប់គ្រងសាច់ប្រាក់រដ្ឋាភិបាលមានភាពសកម្មនៅក្នុងទីផ្សារហិរញ្ញវត្ថុនោះ ដោយហេតុថា សកម្មភាពរបស់ក្រសួងហិរញ្ញវត្ថុប៉ះពាល់ទៅដល់រូបិយវត្ថុភាព (liquidity) របស់ធនាគារពាណិជ្ជកម្ម ដែលធនាគារកណ្តាលមានគលបំណងត្រួតពិនិត្យ តាមរយៈឧបករណ៍គោលនយោបាយរូបិយវត្ថុ (monetary policy instruments) ។ នៅក្នុងការរំកិលទៅរកប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ដែលកាន់តែមានភាពទំនើបនោះ ការទទួលខុសត្រូវដាច់ដោយឡែកពីគ្នារបស់អ្នកគ្រប់គ្រងសាច់ប្រាក់, អ្នកគ្រប់គ្រងបំណុលសាធារណៈ, និងអាជ្ញាធររូបិយវត្ថុ អាចត្រូវតែត្រូវបានកំណត់អោយបានច្បាស់លាស់ជាងនេះនៅក្នុងអនុសារណៈនៃការយោគយល់គ្នា ដែលត្រូវបានធ្វើបច្ចុប្បន្នភាព ។

# ឯកសារយោង

Agence France Trésor (AFT), 2006, *Annual Report, 2005-06*, available via Internet: http://www.aft.gouv.fr.

—— 2007, *Cash Management in 10 questions*, available via Internet: http://www.aft.gouv.fr/aft_ en_21/cash_management_56/in_10_481/index.html#957.

International Monetary Fund, 1999, *Location of Government Deposits: Implications for Monetary Operations*, Monetary and Exchange Affairs Department Operational Paper, MAE OP/99/2, July (Washington).

International Monetary Fund and World Bank, 2001, *Developing Government Bond Markets: A Handbook* (Washington).

International Monetary Fund and World Bank, 2003, *Guidelines for Public Debt Management* (Washington).

IMF, 2007, "Northern Star: Canada's Path to Economic Prosperity", IMF Occasional Paper 258 (Washington).

Rascoe, Mary, 2007, "Managing the Nation's Money," presentation made at the sixteenth Annual Government Financial Management Conference, Financial Management Service, U.S. Department of the Treasury, Washington, D.C.

Storkey, Ian, 2003, *Government Cash and Treasury Management Reform*, Asian Development Bank, Governance Brief, Issue 7-2003, www.asiandevbank.org/Documents/Periodicals/GB/ GovernanceBrief07.pdf.

Swedish National Debt Office, 2006, *Concentrated Activities Lead to Efficient Financial Management*, Forecast and Analysis 2006:2, https://www.riksgalden.se/default_EN____1559.aspx.

Williams, Mike, 2003, *Forecasting Government Cash Flows in the United Kingdom*. Available via Internet: http://www.mj-w.net/cac_gov_cash.html.

Williams, Mike, 2004, *Government Cash Management: Good and Bad Practice*. Available via Internet: http://www.mj-w.net/cac_gov_cash.html.

Wheeler, Graeme, 2004, *Sound Practice in Government Debt Management*, (Washington: World Bank).